Lawyers,
Conflict & Transition



# ប្រសិទ្ធភាពនៃគណៈមេធាវ
# នៅពេលមានវវាទ និងវបត្ត

ខែធ្នូ 2016

E·S·R·C ECONOMIC & SOCIAL RESEARCH COUNCIL

Queen's University Belfast

Ulster University

TJI Transitional Justice Institute

# ប្រសិទ្ធភាពនៃគណៈមេធាវីនៅពេលមានវិវាទ និងវិបត្តិ

## មាតិកា

អារម្ភកថា ........................................................................................ 1
ការទទួលស្គាល់ និងការបដិសេធ ....................................................................... 3
សេចក្តីសង្ខេប ...................................................................................... 4
សេចក្តីផ្តើម ....................................................................................... 7
I. ស្តង់ដារអន្តរជាតិ ................................................................................ 9
ការធានាឯករាជ្យភាពនៃវិជ្ជាជីវៈច្បាប់ ............................................................. 10
ការធានាទទួលបានសេវាកម្មច្បាប់ .................................................................. 10
បទបញ្ញត្តិ និងការបណ្តុះបណ្តាល .................................................................. 11
ការការពារវិធាននៃច្បាប់ ............................................................................ 13
II. ស្តង់ដារជាតិ ..................................................................................... 15
បេសកកម្ម និងអាណត្តិ ............................................................................. 15
ការរៀបចំ និងរចនាសម្ព័ន្ធគណៈមេធាវី ............................................................. 16
ការរៀបចំកម្មវិធី .................................................................................... 18
III. តួនាទីគណៈមេធាវីនៅពេលមានវិវាទ និងវិបត្តិ ............................................. 22
សន្និដ្ឋាន – តើមានស្តង់ដារសម្រាប់គណៈមេធាវីដែលមានប្រសិទ្ធភាពឬទេ? ........................... 29
ឯកសារយោង ........................................................................................ 31

# អារម្ភកថា

របាយការណ៍នេះ ត្រូវបានគេដាក់ឲ្យស្ថិតក្រោមផ្នែកមួយនៃគម្រោង *Lawyers, Conflict & Transition* ដែលជាគំនិតផ្តួចផ្តើមរយៈពេលបីឆ្នាំ ឧបត្ថម្ភមូលនិធិដោយក្រុមប្រឹក្សាស្រាវជ្រាវសង្គម និងសេដ្ឋកិច្ច។

គម្រោងដែលធំជាងនេះ ស្វែងយល់ពីតួនាទីមេធាវីនៅអំឡុងពេលមានវិវាទ របបផ្តាច់ការ និងការផ្លាស់ប្តូររបបនយោបាយ។ បើទោះជាមានមជ្ឈការនៃវិធានច្បាប់ចំពោះទ្រឹស្តីសហសម័យ និងការគោរពយុត្តិធម៌សម័យអន្តរកាលក៏ដោយ ក៏មានការសង្កត់ធ្ងន់តិចតួចផ្នែកអក្សរសាស្ត្រដែលពាក់ព័ន្ធចំពោះតួនាទីមេធាវីនៅក្រៅប្រព័ន្ធតុលាការ ឬការពិតជា "មនុស្សពិតប្រាកដ" ដែលបម្រើការក្នុងប្រព័ន្ធនេះ។

ការសន្និដ្ឋានពីករណីសិក្សាសំខាន់ៗចំនួនប្រាំមួយ (កម្ពុជា ឈីលី អ៊ីស្រាអែល ប៉ាឡេស្ទីន ទុយណេស៊ី និងអាហ្វ្រិកខាងត្បូង) យើងបានចាប់ផ្តើមបង្កើតគម្រោងប្រៀបធៀប និងអត្ថបទខ្លីៗសម្រាប់ការគោរពច្បាប់ក្នុងដំណាក់កាលប្រវត្តិសាស្ត្រនៅក្នុងសង្គមអន្តរកាល និងមានវិវាទ។ ដោយប្រកាន់យកវិធីសាស្ត្រទាំងមូលចំពោះតួនាទី និងមុខងារនៃច្បាប់ និងមេធាវី គម្រោងនេះមានបំណងធ្វើជាចំណុចយុទ្ធសាស្ត្រមួយនៅចន្លោះយុត្តិធម៌សម័យអន្តរកាល និងសង្គមវិទ្យានៃវិជ្ជាជីវៈច្បាប់។
បុគ្គលិកគម្រោង មានមូលដ្ឋាននៅមហាវិទ្យាល័យនីតិសាស្ត្រ នៃសកលវិទ្យាល័យ Queen's University Belfast និងនៅវិទ្យាស្ថានយុត្តិធម៌អន្តរកាល នៃសាកលវិទ្យាល័យ Ulster University។

គម្រោងនេះមានចំណុចសំខាន់របស់ខ្លួន ដែលមានលំដាប់ខ្ពាត "ពិភពលោកជាក់លាក់" ហើយខិតខំដើម្បីធ្វើឲ្យមានភាពខុសប្លែកមួយ ចំពោះទ្រឹស្តី និងការអនុវត្តន៍។ ក្រៅពីលទ្ធផលនៃការសិក្សា យើងតាំងចិត្តក្នុងការបង្កើតគណៈកម្មការការងារមួយ ដែលនឹងជួយដល់សង្គមនានា ដែលយើងបានសិក្សាស្រាវជ្រាវ។ យើងក៏បានដឹងពីដំបូងផងដែរថា បុគ្គលិកចុះស្រាវជ្រាវតាមមូលដ្ឋានជួនកាលមានអារម្មណ៍ថាមានកំហុស "ពេលមកដល់ទីវាល ឬតំបន់ស្រាវជ្រាវដែលទទួលបានអ្វីត្រូវការ" ហើយបន្ទាប់មកវិលត្រឡប់ផ្ទះវិញដោយគ្មានគិតអំពីតម្រូវការប្រជាពលរដ្ឋដែលបានជួយពួកគេស្រាវជ្រាវ ដោយមានអត្ថប្រយោជន៍តិចតួចដែលអាចបង្ហាញបានសម្រាប់អ្នកចូលរួម។ ជាផ្នែកមួយនៃគោលនយោបាយចរិយាមាយាទរបស់យើង យើងបានបង្កើតរបាយការណ៍ដែលតម្រង់ទៅលើការអនុវត្តន៍មួយស៊េរី ដែលមានរៀបចំគម្រោងយ៉ាងពិសេសសម្រាប់យុត្តាធិការនីមួយៗដែលស្ថិតក្រោមការពិនិត្យពិច័យ ក៏ដូចជាឯកសារសង្ខេបសម្រាប់ប្រិយមិត្តអ្នកអានអន្តរជាតិ។

បុគ្គលទាំងឡាយដែលគេបានសម្ភាសសម្រាប់គម្រោងធំជាងនេះ (ជាង 120 នាក់) ត្រូវបានគេអញ្ជើញឲ្យលើកជាប្រធានបទស្រាវជ្រាវ និងអត្ថបទខ្លីៗ ដែលមានការពាក់ព័ន្ធពួកគេដោយផ្ទាល់ និងបណ្តាអង្គការ និងបណ្តាញផ្សេងៗដែលពួកគេធ្វើការជាមួយ។ ក្រុមស្នូល បានទទួលនិងវិភាគយោបល់ទាំងនេះ ហើយធ្វើការ

លើរបាយការណ៍សំខាន់ពីរក្នុងមួយយុត្តាធិការ។ ក្នុងករណីខ្លះ ការងារបានបញ្ចប់ដោយបុគ្គលិកខាងក្នុង ហើយករណីខ្លះទៀត យើងដកចេញពីធនធាន និងទីប្រឹក្សាអន្តរជាតិរបស់យើង។

របាយការណ៍ទាំងនេះ ត្រូវបានគេរៀបចំឲ្យមានតម្លៃសម្រាប់អ្នកអនុវត្តភ្លាមៗ ដូច្នេះយើងបានខិតខំបញ្ចៀសការប្រើប្រាស់ពាក្យពេចន៍ និងភាសាដែលពិបាកយល់។ យើងមានអត្ថបទជាភាសាអង់គ្លេស និងភាសាតំបន់ដែលពាក់ព័ន្ធ។

អ្វីៗដែលប្រិយមិត្តអ្នកអានរំពឹងទុក ឆ្លុះបញ្ចាំងពីអ្នកដែលចូលរួមផ្តល់បទសម្ភាសន៍ជាច្រើន ដូចជា៖

- អ្នកជំនាញផ្នែកច្បាប់ជាតិ និងអន្តរជាតិ (រួមទាំងមេធាវីដែលទាក់ទងប្រយោជន៍សាធារណៈ/ដែលព្យាយាមដោះស្រាយបញ្ហា និង មេធាវីរដ្ឋ)
- សិស្ស ឬនិស្សិតដែលចាប់អារម្មណ៍លើតួនាទីរបស់មេធាវី ជាអ្នកដើរតួខាងនយោបាយ និងសង្គម (ដោយផ្តោតជាពិសេសលើយុត្តិធម៌សម័យអន្តរកាល)
- មន្ត្រីរដ្ឋាភិបាល
- អ្នកតាក់តែងគោលនយោបាយអន្តរជាតិ
- សកម្មជនសង្គមស៊ីវិល
- អ្នកកាសែត និងអ្នកធ្វើអត្ថាធិប្បាយដទៃទៀត

ស៊េរីរបាយការណ៍ទាំងមូលនឹងអាចរកបាននៅតាមវែបសាយថ៍របស់យើងដែលមានអាសយដ្ឋាន (www.lawyersconflictandtransition.org) ហើយនឹងផ្សព្វផ្សាយតាមបណ្តាញ និងគណនី Twitter របស់យើងផ្សេងៗគ្នា (@lawyers_TJ)។

យើងសង្ឃឹមថា លោកអ្នកនឹងរីករាយអានរបាយការណ៍នេះ ហើយយើងសូមលើកទឹកចិត្តឲ្យលោកអ្នកទាំងអស់គ្នាផ្សព្វផ្សាយបន្តតាមបណ្តាញរបស់លោកអ្នកផងដែរ។

សម្រាប់ព័ត៌មានបន្ថែមអំពីគម្រោងធំជាងនេះ សូមទាក់ទងមកយើងខ្ញុំដោយសេរី តាមអាសយដ្ឋាន៖ www.lawyersconflictandtransition.org/contact



--------------------------------

Kieran McEvoy PhD

នាយកគ្រប់គ្រងគម្រោង *Lawyers, Conflict and Transition* Project

ខែធ្នូ 2016

# ការទទួលស្គាល់ និងការបដិសេធ

របាយការណ៍នេះ បានរៀបចំឡើងដោយ Jonathan Porter ក្រោមកិច្ចសហការជាមួយគម្រោង *Lawyers, Conflict and Transition* ។ រាល់ទស្សនៈទាំងអស់ដែលបានបញ្ចេញ និងរាល់កំហុសទាំងឡាយ នៅតែជាការទទួលខុសត្រូវរបស់អ្នកនិពន្ធ។

របាយការណ៍នេះ ត្រូវបានរៀបចំឡើងដែលអាចប្រើប្រាស់ដោយឥតគិតថ្លៃ។ ទស្សនៈ និងយោបល់នានាដែលមានក្នុងរបាយការណ៍ គឺជាទស្សនៈ និងយោបល់របស់អ្នកនិពន្ធ មិនមែនជារបស់ក្រុមប្រឹក្សាស្រាវជ្រាវសេដ្ឋកិច្ច និងសង្គមឡើយ។ លោកអ្នកអាចប្រើប្រាស់ និងថតចម្លងរបាយការណ៍ទាំងមូល និងដោយផ្នែកសម្រាប់គោលបំណងអប់រំ បើសិនលោកអ្នកៈ (i) មិនកែប្រែ ឬប្រែសម្រួលខ្លឹមសារ (ii) ប្រើប្រាស់ឯកសារនេះក្នុងគោលបំណងមិនរកប្រាក់ចំណេញ និង (iii) ទទួលស្គាល់ការរក្សាសិទ្ធិរបស់ម្ចាស់ និងប្រភពក្នុងការដកស្រង់ណាមួយពីរបាយការណ៍នេះ។

ចំពោះទំហំដ៏ពេញលេញដែលបានអញ្ញាតដោយច្បាប់ អ្នកនិពន្ធ មិនទទួលខុសត្រូវទាំងស្រុងចំពោះការប្រើប្រាស់របស់លោកអ្នកចំពោះរបាយការណ៍នេះឡើយ។ អ្នកនិពន្ធនានា ការពារសិទ្ធិប្រកបដោយសីលធម៌របស់ពួកគេស្ថិតក្រោមច្បាប់ស្ដីពីការរៀចំការរក្សាសិទ្ធិ (Copyright Designs) និងច្បាប់ប៉ាតង់ ឆ្នាំ 1988 ដើម្បីឲ្យកំណត់អត្តសញ្ញាណជាអ្នកនិពន្ធដែលមានស្នាដៃ។

**ISBN:** 9781909131576

# សេចក្តីសង្ខេប

- គណៈមេធាវី (ដែលគេស្គាល់ផងដែរថាជា ក្រុមប្រឹក្សាមេធាវី និងសង្គមអ្នកច្បាប់) ជាញឹកញាប់ត្រូវបានគេបង្កើតឡើងដើម្បីផ្តល់ជូនការសម្តែងមតិយោបល់រួមមួយនៅក្នុងវិជ្ជាជីវៈច្បាប់ ហើយក៏ដើរតួនាទីផ្សេងទៀត រួមមាន៖ បទបញ្ញត្តិនៃវិជ្ជាជីវៈច្បាប់ ការការពារវិធាននៃច្បាប់ និងការចូលរួមក្នុងកំណែទម្រង់ច្បាប់។
- ស្តង់ដារអន្តរជាតិអំពីបទបញ្ញត្តិ និងប្រសិទ្ធភាពនៃគណៈមេធាវី ត្រូវបានបង្កើតឡើងដោយអង្គការសហប្រជាជាតិ (UN)។ ស្តង់ដារទាំងនេះ រួមមានគោលការណ៍មូលដ្ឋានរបស់អង្គការសហប្រជាជាតិអំពីតួនាទីមេធាវី ដែលសំដៅសំខាន់ទៅលើមេធាវីម្នាក់ ប៉ុន្តែក៏មានបញ្ចូលគោលការណ៍ណែនាំ និងអនុសាសន៍នានាសម្រាប់គណៈមេធាវីផងដែរ។ អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិអំពីឯករាជ្យភាពនៃមេធាវី និងចៅក្រម ក៏បានបង្កើតគោលការណ៍ណែនាំសម្រាប់គណៈមេធាវីផងដែរ។
- គណៈមេធាវីអន្តរជាតិ ធ្វើការផ្សព្វផ្សាយជាទៀងទាត់នូវរបាយការណ៍ សេចក្តីប្រកាស និងសេចក្តីណែនាំអំពីមុខងារដ៏មានប្រសិទ្ធភាពរបស់គណៈមេធាវីជាតិ។
- ស្តង់ដារអន្តរជាតិអំពីតួនាទីគណៈមេធាវី បញ្ជាក់ថា ពួកគេគួរតែសកម្មលើ៖
    - <u>ការការពារភាពឯករាជ្យនៃវិជ្ជាជីវៈច្បាប់។</u> គណៈមេធាវី ដើរតួនាទីយ៉ាងសកម្ម ក្នុងការធានាឲ្យបានថា វិជ្ជាជីវៈច្បាប់ គឺគ្មានការរំខានពីរដ្ឋឡើយ ហើយមេធាវីម្នាក់ៗ អាចបំពេញការងាររបស់ពួកគេ ដោយគ្មានការបៀតបៀនរំខាន ឬគំរាមកំហែងឡើយ។ សារៈសំខាន់នៃតួនាទីនេះ គឺទាំងអស់ដែលកើតមាន នៅពេលមានវិបត្តិ ឬវិវាទ ដែលអាជ្ញាធររដ្ឋ អាចប៉ុនប៉ងត្រួតពិនិត្យ ឬមើលពីលើការគ្រប់គ្រងផ្នែកយុត្តិធម៌ និងវិជ្ជាជីវៈច្បាប់ជាទូទៅ។
    - <u>ការធានាទទួលបានយុត្តិធម៌។</u> ស្តង់ដារអន្តរជាតិ បង្ហាញថា គណៈមេធាវី គួរផ្តល់ការគាំទ្រដល់បុគ្គលដែលស្វែងរកជំនួយផ្លូវច្បាប់ ជាពិសេសទៅដល់ប្រជាពលរដ្ឋក្រីក្រ និងមធ្យម។ ឧទាហរណ៍ តាមរយៈការដកយករនាំងឧបសគ្គនានាចំពោះការទទួលបានសេវាកម្មផ្នែកច្បាប់ និងការផ្តល់សេវាកម្មច្បាប់ដោយឥតគិតប្រាក់កម្រៃ ជាពិសេសអតិថិជនមានប្រាក់ចំណូលទាប។ តួនាទីនេះ មានសារៈសំខាន់ណាស់នៅពេលមានវិបត្តិ ពេលក្រុមប្រជាពលរដ្ឋដែលមានជីវភាពមធ្យម អាចត្រូវបានគេផ្តោតជាគោលដៅ ហើយទំនងជាត្រូវការជំនួយសេវាកម្មផ្នែកច្បាប់។
    - <u>បទបញ្ញត្តិ និងការបណ្តុះបណ្តាល។</u> ដោយមិនគិតពីរចនាសម្ព័ន្ធ ឬយុត្តាធិការក្នុងការងាររបស់ពួកគេ គណៈមេធាវី ត្រូវតែធ្វើនិយតកម្ម ហើយបណ្តុះបណ្តាលសមាជិករបស់ពួកគេ ដែលរួមមានការធ្វើនិយតកម្មសីលធម៌ នីតិវិធីក្នុងការដាក់ពិន័យ និងការផ្តល់ការអប់រំផ្នែកច្បាប់បន្ត។

   - ការការពារវិធាននៃច្បាប់។ ជាការសម្ដែងមតិយោបល់រួមគ្នាខាងវិជ្ជាជីវៈច្បាប់ គណៈមេធាវីបម្រើការជាអ្នកនៅជួរមុខក្នុងការការពារច្បាប់ ជាពិសេសក្នុងកំឡុងពេលមានវិបត្តិ។ នេះអាចចាំបាច់សម្រាប់សកម្មភាពនយោបាយ ដែលការគ្រប់គ្រងវិស័យយុត្តិធម៌ និងការប្រព្រឹត្តរបស់ចៅក្រមដែលពាក់ព័ន្ធ។
- បន្ថែមលើស្តង់ដារអន្តរជាតិទាំងនេះ ទម្លាប់អនុវត្តល្អថ្នាក់ជាតិក៏ផ្តល់ការណែនាំបន្ថែមអំពីបេសកកម្ម និងអាណត្តិ ការរៀបចំ និងរចនាសម្ព័ន្ធ និងកម្មវិធីផងដែរ។
- ទំនួលខុសត្រូវ និងតួនាទីគណៈមេធាវីក្នុងយុត្តាធិការ ដែលមានវិបត្តិ និងវិវាទ ជាញឹកញាប់ គឺពិបាកកំណត់អត្តសញ្ញាណថែមទៀត។ ភាពឯករាជ្យនៃវិជ្ជាជីវៈច្បាប់ អាចត្រូវបានគេគំរាមកំហែង ច្បាប់មានភាពទន់ខ្សោយ ឬការរាលដាលអំពើពុករលួយ ដែលបណ្តាលឲ្យមានបញ្ហាច្រើនសម្រាប់មុខងារដ៏មានប្រសិទ្ធភាពរបស់គណៈមេធាវី។ ស្តង់ដារអន្តរជាតិ មានរៀបចំឯកសារយោងតិចតួចចំពោះស្ថានភាពទាំងនេះ ហើយត្រូវបានសន្និដ្ឋានយ៉ាងច្រើនពីករណីសិក្សា និងការឆ្លើយតបអន្តរជាតិ។
- វិសាលភាពនៃគណៈមេធាវីដែលគួររក្សាគោលជំហរអព្យាក្រិត ឬឆ្លើយតបយ៉ាងសកម្មនឹងវិបត្តិរាប់ទាំងការរំលោភសិទ្ធិមនុស្ស និងការគំរាមកំហែងចំពោះវិធាននៃច្បាប់ ត្រូវបានគេពិភាក្សា។
- គណៈមេធាវីខ្លះ មានភាពសកម្មជាពិសេស នៅពេលមានវិវាទ ឬមានភាពផ្តាច់ការនិយម។ កន្លែងណាដែលគណៈមេធាវី មានភាពស្ងប់ស្ងាត់ចំពោះមុខនៃការរំលោភសិទ្ធិមនុស្ស និងការវាយប្រហារមកលើច្បាប់ កន្លែងនោះពួកគេកំពុងប្រឈមនឹងការរិះគន់ហើយ។
- អំពើពុករលួយក្នុងយុត្តាធិការ ដែលកំពុងមានវិបត្តិ បង្កបញ្ហាជាពិសេសដល់គណៈមេធាវី ដូចជាអតិថិជននិយម អាចធ្វើឲ្យប៉ះពាល់ដល់ការគ្រប់គ្រង និងសកម្មភាពនានារបស់គណៈមេធាវីខ្លួនឯងផ្ទាល់។
- បើទោះជាមានបញ្ហាប្រឈមទាំងនេះក៏ដោយ ការវិភាគនៃទង្វើអសកម្ម និងការងារមេធាវីមានប្រសិទ្ធភាពក្នុងករណីខ្លះ ក្នុងការជំរុញគណៈមេធាវីឲ្យចូលរួមពាក់ព័ន្ធកាន់តែសកម្មខ្លាំងឡើងក្នុងការឆ្លើយតបនឹងវិបត្តិ។
- នៅតែមានតម្រូវការសម្រាប់ស្តង់ដារលម្អិតបន្ថែម និងការណែនាំអំពីតួនាទី និងការទទួលខុសត្រូវនៃគណៈមេធាវីក្នុងបរិយាកាសមានវិបត្តិ ឬវិវាទ។ ស្តង់ដារទាំងនេះ គួរតែត្រូវបានគេបង្កើតឡើង ដោយឈរលើបញ្ហាដូចជា៖
   - គណៈមេធាវី គួរប្រកាន់ជំហរនៅពេលការពារវិធាននៃច្បាប់ និងការរំលោភសិទ្ធិមនុស្សនៅពេលណា និងរបៀបណា។

- ការធានាទទួលបានសេវាកម្មផ្នែកច្បាប់ ដោយឥតយកប្រាក់ឈ្នួល ជាពិសេសនៅទីណាដែលមានវិបត្តិ ឬវិវាទកើតឡើងចំពោះពលរដ្ឋដែលមានជីវភាពមធ្យម ឬសហគមន៍ជនជាតិភាគតិច ហើយសម្របសម្រួលលទ្ធភាពពួកគេឲ្យទទួលបានសេវាកម្មបែបនេះ។
- របៀបការពារភាពឯករាជ្យនៃវិជ្ជាជីវៈច្បាប់ពីការរំខានរបស់រដ្ឋ ក្នុងពេលមានវិបត្តិ។
- យន្តការការពារមេធាវី និងស្វែងរកយុត្តិធម៌សម្រាប់មេធាវី ដែលអាយុជីវិតរបស់ពួកគេកំពុងមានការគំរាមកំហែងចំពោះជនទាំងឡាយណាដែលត្រូវបានគេសម្លាប់ ដោយសារមូលហេតុការងាររបស់ពួកគេ។

# សេចក្ដីផ្ដើម

គណៈមេធាវី ក្រុមប្រឹក្សាមេធាវី និងសង្គមអ្នកច្បាប់[1] បានក្លាយជាស្ដង់ដារពិសេសមួយនៃប្រព័ន្ធច្បាប់សម័យទំនើប។ ជាញឹកញាប់ វាត្រូវបានគេបង្កើតឡើងដើម្បីផ្ដល់ជូនការសម្ដែងមតិរួមគ្នានៅក្នុងវិជ្ជាជីវៈច្បាប់ ហើយមានតួនាទីផ្សេងទៀត ដូចជាបទបញ្ញត្តិនៃវិជ្ជាជីវៈច្បាប់ ការការពារច្បាប់ និងការលើកកម្ពស់កំណែទម្រង់ច្បាប់។ គណៈមេធាវីសម័យទំនើបភាគច្រើន មានអាណត្តិស្រដៀងគ្នា ដែលបម្រើផលប្រយោជន៍ដល់ក្រុមគោលដៅបីៈ មេធាវីផ្ទាល់ខ្លួន វិជ្ជាជីវៈច្បាប់ទាំងអស់ និងសាធារណៈជន ជាទូទៅ។[2]

គណៈមេធាវី មានទម្រង់បែបបទខុសគ្នាជាច្រើន អាស្រ័យលើយុត្តាធិកា។ ទម្រង់បែបបទខ្លះ គឺជាគណៈមេធាវី ដែលគេតម្រូវឲ្យមាន និងតាមបញ្ញត្តិ ដែលសមាជិកត្រូវតែមានកាតព្វកិច្ចដើម្បីប្រកបវិជ្ជាជីវៈច្បាប់ដោយស្របច្បាប់ ចំណែកទម្រង់បែបបទខ្លះទៀត គឺស្ម័គ្រចិត្ត ឬមានកំណត់ចំពោះក្រុមពិសេសណាមួយ ដែលអាចបម្រើវិស័យច្បាប់ជាក់លាក់ណាមួយ ឬត្រូវបានគេបម្រុងទុកសម្រាប់ក្រុមភាគតិច នៃអ្នកជំនាញផ្នែកច្បាប់។[3] ដោយស្មើៗគ្នា គណៈមេធាវីខ្លួនឯង គឺជាយុត្តាធិការ ដែលពួកគេមានមុខងារ។ គណៈមេធាវីខ្លះ ចេញបទបញ្ញត្តិវិជ្ជាជីវៈច្បាប់ក្នុងបរិយាកាសនយោបាយ និងសង្គម ដែលច្បាប់មានកម្លាំងរឹងមាំ ហើយដែលវិជ្ជាជីវៈមេធាវី មានភាពឯករាជ្យពេញលេញ។ ប៉ុន្តែគណៈមេធាវីដទៃទៀត ត្រូវតែបំពេញភារៈកិច្ចរបស់ពួកគេ នៅចំពេលមានជម្លោះប្រដាប់អាវុធ គ្រោះមហន្តរាយធម្មជាតិ ភាពច្របូកច្របល់ខាងនយោបាយ ឬវិបត្តិដែលកំពុងរាលដាលដទៃទៀត ដែលគំរាមកំហែងដល់ច្បាប់ សិទ្ធិមនុស្ស និងភាពឯករាជ្យនៃវិជ្ជាជីវៈច្បាប់។

ដោយគិតអំពីភាពផ្សេងៗគ្នានៃគណៈមេធាវី និងវិសាលភាពនៃយុត្តាធិការ ដែលពួកគេប្រតិបត្តិ តើមានការអនុវត្តល្អជាមូលដ្ឋានណាមួយ ដែលកំណត់និយមន័យ ឬបញ្ជាក់លក្ខណៈពីគណៈមេធាវីដែលមានប្រសិទ្ធភាពទេ? ក្រៅពីនេះ ក្នុងករណីដែលមានភាបច្របូកច្របល់ខាងនយោបាយ ឬសង្គម តើគណៈមេធាវីដែលមានប្រសិទ្ធភាព មានតួនាទី និងការទទួលខុសត្រូវអ្វីខ្លះ ហើយអនុវត្តយ៉ាងដូចម្ដេច? ឯកសារស្រាវជ្រាវនេះ ពិនិត្យមើលអំពីស្ដង់ដាររួមនៃគណៈមេធាវី ដើម្បីកំណត់ថា លក្ខណៈវិនិច្ឆ័យអ្វីខ្លះដែលមានស្រាប់ ដើម្បីវាស់ស្ទង់

[1] នៅក្នុងអត្ថបទនេះ ពាក្យទាំងនេះ នឹងត្រូវបានគេចាត់ទុកថាជាសទិសន័យ ហើយពាក្យ "គណៈមេធាវី" នឹងត្រូវបានគេប្រើប្រាស់។

[2] Quintin Johnstone, 'គណៈមេធាវីៈ គោលនយោបាយ និងការអនុវត្ត' *Yale Law and Policy Review* 15(193), 1996 p.195.

[3] យុត្តាធិការជាច្រើន មានគណៈមេធាវីមួយ ជាតម្រូវការសម្រាប់ការប្រកបវិជ្ជាជីវៈច្បាប់ ហើយអាចមានគណៈមេធាវីបន្ថែម ដោយស្ម័គ្រចិត្ត ដើម្បីតំណាងផលប្រយោជន៍ពិសេស។ ឧទាហរណ៍ ប្រទេសឥណ្ឌា តម្រូវឲ្យមេធាវីទាំងអស់ ចុះឈ្មោះជាមួយក្រុមប្រឹក្សាមេធាវីឥណ្ឌា ដើម្បីអាចប្រកបវិជ្ជាជីវៈខ្លួនបាន ដែលធ្វើឲ្យគណៈមេធាវីស្ថិតក្រោមអណត្តិនៃច្បាប់។ នៅសហរដ្ឋអាមេរិក រដ្ឋភាគច្រើន តម្រូវឲ្យមានសមាជិកភាពក្នុងគណៈមេធាវីរដ្ឋ ដើម្បីអាចប្រកបវិជ្ជាជីវៈបាន។ គណៈមេធាវីដែលស្ម័គ្រចិត្ត មានដូចជាគណៈចាត់តាំងឯកជនដែលមិនតម្រូវដោយបញ្ញត្តិ ឧទាហរណ៍សហព័ន្ធមេធាវីស្ត្រីនៅប្រទេសកេនយ៉ា សមាគមអារ៉ាប់សម្រាប់អាជ្ញាកណ្ដាលអន្តរជាតិនៅប្រទេសបារាំង ឬគណៈមេធាវីស្ម័គ្រចិត្តមួយក្នុងចំណោមគណៈមេធាវីជាច្រើន – គណៈមេធាវីអាមេរិកាំង។

ប្រសិទ្ធភាពរបស់ពួកគេ ទាំងក្នុងពេលមានសន្តិភាព និងវិវាទ។ ផ្នែកដំបូង មើលទៅលើក្របខ័ណ្ឌការងារអន្តរជាតិ ហើយរកមើលថាស្តង់ដារទាំងនោះមាននៅកន្លែងណាទាក់ទងនឹងតួនាទី និងការទទួលខុសត្រូវរបស់គណៈមេធាវី និងកន្លែងណាទៀត ដែលត្រូវការឲ្យមានការអភិវឌ្ឍន៍។ ផ្នែកទីពីរ មើលទៅលើនិន្នាការ និងចំណុចរួមនៃភាពខុសប្លែកគ្នា ក្នុងចំណោមគណៈមេធាវីផ្សេងៗ ដើម្បីរកឲ្យឃើញនូវការអនុវត្តន៍ល្អ និងស្តង់ដារជាតិដែលធ្វើឲ្យគណៈមេធាវីដែលមានប្រសិទ្ធភាព។ ផ្នែកចុងក្រោយ វិភាគទៅលើចន្លោះប្រហោងសម្រាប់យុត្តាធិការដែលជួបប្រទះវិបត្តិ ឬវិវាទ។ ជាពិសេសផ្នែកនេះ ផ្តោតទៅលើតម្រូវការដើម្បីអភិវឌ្ឍស្តង់ដារ និងបទដ្ឋានគតិយុត្តិសម្រាប់គណៈមេធាវី ដែលដើរតួនាទីក្នុងពេលមានអាសន្ន និងក្នុងបរិយាកាស ដែលមានហានិភ័យខ្ពស់។

# I. ស្តង់ដារអន្តរជាតិ

ដូចគ្នានឹងអ្នកជំនាញផ្នែកវេជ្ជសាស្ត្រផងដែរ មេធាវីគឺជាវិជ្ជាជីវៈតែមួយគត់ ដែលមានស្តង់ដារអភិវឌ្ឍខ្ពស់ និងមានរចនាសម្ព័ន្ធ នៅក្របខ័ណ្ឌអង្គការសហប្រជាជាតិ។[4] គោលការណ៍មូលដ្ឋានរបស់អង្គការសហប្រជាជាតិ អំពីតួនាទីរបស់មេធាវី ចែងពីកាតព្វកិច្ចនានារបស់វិជ្ជាជីវៈច្បាប់ ក្នុងការធានាឲ្យបាននូវមុខងារដ៏មានប្រសិទ្ធភាពរបស់ខ្លួន និងលើកទឹកចិត្តឲ្យមានការគោរពសិទ្ធិមូលដ្ឋាន។ ជាពិសេស មេធាវី ត្រូវ "លើកកម្ពស់សិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន ដែលទទួលស្គាល់ដោយច្បាប់ជាតិ និងអន្តរជាតិ" ហើយ "ធ្វើសកម្មភាពស្របតាមច្បាប់ និងស្តង់ដារដែលគេ ទទួលស្គាល់ និងក្រមសីលធម៌វិជ្ជាជីវៈច្បាប់។"[5] គោលការណ៍មូលដ្ឋាន ទទួលស្គាល់តួនាទីដ៏សំខាន់នៃគណៈមេធាវីក្នុង "ការលើកស្ទួយស្តង់ដារ និងសីលធម៌វិជ្ជាជីវៈ ការការពារសមាជិករបស់ខ្លួនពីការបំពារបំពាន និងការដាក់កម្រិតដោយមិនសមរម្យ និងការរំលោភបំពាននានា ការផ្តល់សេវាផ្នែកច្បាប់ទៅដល់អ្នកដែលមានតម្រូវការ និងការសហការជាមួយរដ្ឋាភិបាល និងស្ថាប័នដទៃទៀតដើម្បីយុត្តិធម៌ និងផលប្រយោជន៍សាធារណៈ។"[6] លើសពីនេះ គោលការណ៍មូលដ្ឋាន ទទួលស្គាល់ផងដែរថា សិទ្ធិ និងសេរីភាពមូលដ្ឋានទាំងនេះ តម្រូវឲ្យទទួលបានវិជ្ជាជីវៈច្បាប់ ដែលនៅតែឯករាជ្យគ្រប់ពេលវេលា។[7] តម្រូវការទាំងនេះ ត្រូវបានអភិវឌ្ឍបន្ថែមដោយអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ អំពីឯករាជ្យភាពនៃចៅក្រម និងមេធាវីដែលបានពិភាក្សា ដូចខាងក្រោម។

ក្រៅពីនេះ គណៈមេធាវីអន្តរជាតិ (IBA) ផ្តល់ការណែនាំសំខាន់ៗជាច្រើនអំពីការអនុវត្តន៍ល្អ សម្រាប់គណៈមេធាវីក្នុងស្រុក ដើម្បីអនុវត្តតាម។ ជា "ការសម្តែងមតិយោបល់ជាសកល" នៃវិជ្ជាជីវៈច្បាប់ IBA ខិតខំធ្វើយ៉ាងណាឲ្យមានឥទ្ធិពលដល់ការអភិវឌ្ឍន៍ច្បាប់អន្តរជាតិ ហើយតម្រង់ទិសដៅអនាគតនៃវិជ្ជាជីវៈច្បាប់ទូទាំងពិភពលោក។[8] សកម្មភាពក្នុងចំណោមសកម្មភាពសំខាន់ៗរបស់ IBA គឺការគាំទ្រគណៈមេធាវីទូទាំងពិភពលោក។ ការណ៍នេះរាប់បញ្ចូលទាំងការគាំទ្រសម្រាប់ការអភិវឌ្ឍន៍គណៈមេធាវី និងការអនុវត្តន៍ល្អៗ ក្នុងអភិបាលកិច្ច និងមុខនាទីរបស់ពួកគេ។[9] ស្តង់ដារទូទៅទាំងនេះ ជាមួយនឹងស្តង់ដារទាំងឡាយ ដែលមានក្នុងគោលការណ៍មូលដ្ឋានរបស់អង្គការសហប្រជាជាតិ ត្រូវបានគេយកមកវិភាគ ដូចខាងក្រោម។

[4] Kieran McEvoy, 'តើមេធាវីបានធ្វើអ្វីខ្លះនៅពេលកើត "សង្គ្រាម"៖ អព្យាក្រិត្យភាព វិវាទ និងវប្បធម៌នៃភាពស្ងៀមស្ងាត់' *The Modern Law Review,* 74(3), 2001, p.383.

[5] គោលការណ៍មូលដ្ឋានរបស់អង្គការសហប្រជាជាតិ ស្តីអំពីតួនាទីរបស់មេធាវី (7 កញ្ញា 1990), para. 14.

[6] *Ibid.* បុព្វកថា

[7] *Ibid.*

[8] វិបសាយថ៍របស់គណៈមេធាវីអន្តរជាតិ, អំពី IBA, អាសយដ្ឋាន http://www.ibanet.org/About_the_IBA/About_the_IBA.aspx, ចូលទស្សនានៅថ្ងៃទី 30 តុលា 2015។

[9] *Ibid.*

ឯករាជ្យភាពនៃវិជ្ជាជីវៈច្បាប់ គឺជាគោលការណ៍មូលដ្ឋាន ដែលចាំបាច់សម្រាប់មុខនាទីដ៏មានប្រសិទ្ធភាពរបស់គណៈមេធាវីមួយ ហើយមានការការពារយ៉ាងរឹងមាំនៅថ្នាក់អន្តរជាតិ។ គោលការណ៍មូលដ្ឋានរបស់អង្គការសហប្រជាជាតិដែលគណៈមេធាវី មានតួនាទីយ៉ាងសំខាន់ក្នុងការការពារមេធាវី និងវិជ្ជាជីវៈច្បាប់ជារួម ដោយគ្មានការរារាំង និងរំលោភបំពានឡើយ។[10] IBA បានទទួលស្គាល់ថា ឯករាជ្យភាពនៃវិជ្ជាជីវៈមេធាវី "បង្កើតឲ្យមានការធានាយ៉ាងសំខាន់សម្រាប់ការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស និងចាំបាច់សម្រាប់សេវាកម្ម ផ្នែកច្បាប់ប្រកបដោយប្រសិទ្ធភាព និងគ្រប់គ្រាន់។"[11] តាមពិត IBA មានកម្មវត្ថុចំបងមួយក្នុងចំណោមកម្មវត្ថុចំបងទាំងបី គឺការរក្សាឯករាជ្យភាពនៃវិជ្ជាជីវៈច្បាប់ និងសិទ្ធិសម្រាប់មេធាវីក្នុងការប្រកបវិជ្ជាជីវៈដោយគ្មានការជ្រៀតជ្រែក។ ដូច្នេះ គណៈមេធាវីដែលមានប្រសិទ្ធភាព ត្រូវតែបម្រើការដើម្បីធានាឲ្យបានថា មេធាវីអាចប្រកប វិជ្ជាជីវៈដោយគ្មានការភិតភ័យ។ ដូចដែលបានពិភាក្សាខាងក្រោមនេះ ឯករាជ្យភាពនៃវិជ្ជាជីវៈច្បាប់ មានសារៈសំខាន់ណាស់នៅពេលមានវិបត្តិ ដែលគណៈមេធាវី និងអ្នកប្រកបវិជ្ជាជីវៈទាំងអស់មានតួនាទីកណ្ដាលក្នុងការរក្សាឲ្យបានវិធាននៃច្បាប់ និងការធានាទទួលបានយុត្តិធម៌។

## ការធានាទទួលបានសេវាកម្មច្បាប់

ស្តង់ដារអន្តរជាតិ តម្រូវឲ្យគណៈមេធាវី មានកាតព្វកិច្ចធានាទទួលបានសេវាកម្មច្បាប់ដល់បុគ្គលគ្រប់រូបនៅក្នុងដែនសមត្ថកិច្ច។ គោលការណ៍មូលដ្ឋានរបស់អង្គការសហប្រជាជាតិ មានបញ្ញត្តិមាត្រាចំនួនបួនអំពីការទទួលបានសេវាកម្មផ្នែកច្បាប់ដោយគ្មានការរើសអើង (ផ្អែកលើបញ្ជីមិនលម្អិតនៃស្ថានភាពសង្គម) និងមានខចែងជាក់លាក់សម្រាប់ជនក្រីក្រ។[12] ក្រៅពីនេះ គណៈមេធាវីត្រូវសហការជាមួយរដ្ឋាភិបាល ដើម្បីធានាឲ្យបានថា គ្រប់បុគ្គលទាំងអស់ អាចទទួលបានសេវាកម្មផ្នែកច្បាប់ដោយស្មើៗគ្នា និងមានប្រសិទ្ធភាព ហើយមានការជួយជ្រោមជ្រែងពីមេធាវី ដោយគ្មានការជ្រៀតជ្រែកដោយមិនសមរម្យណាមួយឡើយ។ (មាត្រា 24-25)។[13] ការទទួលបានសេវាកម្មផ្នែកច្បាប់ មិនត្រឹមតែតម្រូវឲ្យមានមេធាវី និងការដាក់ឲ្យនៅជិតសេវាកម្មបំផុតប៉ុណ្ណោះទេ ថែមទាំងតម្រូវឲ្យមានតម្លៃសមរម្យជាចាំបាច់សម្រាប់សេវាកម្មផ្នែកច្បាប់ ឬការផ្ដល់សេវាកម្មផ្នែកច្បាប់ក្នុងតម្លៃទាប ឬដោយឥតគិតថ្លៃទៅដល់ក្រុម និងបុគ្គលនានា ដែលមិនមានលទ្ធភាពចំណាយ។ គោលការណ៍មូលដ្ឋានអង្គការសហប្រជាជាតិ អំពាវនាវឲ្យបណ្ដារដ្ឋាភិបាលធានាឲ្យបានថា មានធនធានគ្រប់គ្រាន់ដើម្បីឲ្យប្រាកដថា ជនក្រីក្រអាចទទួល

[10] គោលការណ៍មូលដ្ឋាន, បុព្វកថា

[11] គណៈមេធាវីអន្តរជាតិ, ស្តង់ដារ IBA សម្រាប់ឯករាជ្យភាពនៃវិជ្ជាជីវៈច្បាប់, អនុម័តឆ្នាំ 1990។

[12] *Ibid.* paras 1-4.

[13] *Ibid.* paras 24,25.

បានសេវាកម្មទាំងនេះ។[14] ប៉ុន្តែពួកគេក៏បញ្ជាក់ពីតួនាទីដ៏សំខាន់ ដែលគណៈមេធាវីមាននៅក្នុងអង្គការ និងការផ្តល់សេវាកម្មបែបទាំងនេះ ហើយជាពិសេសការផ្តល់លទ្ធភាពឲ្យជនក្រីក្រទទួលបានសេវាកម្ម។[15]

IBA ក៏បានលើកទល្លីករណ៍ថា ការទទួលខុសត្រូវសំខាន់មួយក្នុងចំណោមការទទួលខុសត្រូវសំខាន់ៗជាច្រើនរបស់គណៈមេធាវី គឺផ្សព្វផ្សាយពីសេវាកម្មសាធារណៈឥតគិតថ្លៃ និងការទទួលបានសេវាកម្មស្មើគ្នាសម្រាប់សាធារណៈជន ចំពោះប្រព័ន្ធយុត្តិធម៌ រួមទាំងការផ្តល់ជំនួយ និងដំបូន្មានផ្នែកច្បាប់។[16] ដើម្បីធានាថា គ្មានបុគ្គលណាម្នាក់ ត្រូវបានគេបដិសេធចំពោះយុត្តិធម៌ IBA ក៏បញ្ជាក់ដែរថា គណៈមេធាវី គួររៀបចំផ្តល់សេវាកម្មមេធាវីជូនដល់អ្នកទាំងឡាយណា ដែលគ្មានលទ្ធភាពបង់ថ្លៃសេវាកម្មទាំងនេះ។[17] នៅក្នុង សេចក្តីប្រកាសអំពីច្បាប់ទទួលរ៉ាប់រងដោយមិនគិតថ្លៃឈ្នួល ជាពិសេសអតិថិជនរបស់ខ្លួនមានប្រាក់ចំណូលទាប IBA បានលើកឡើងថា សេវាកម្មច្បាប់ទទួលរ៉ាប់រងដោយមិនគិតថ្លៃឈ្នួល ជាពិសេសអតិថិជនមានប្រាក់ចំណូលទាបបែបនេះ គឺជាផ្នែកដ៏សំខាន់នៃវិជ្ជាជីវៈច្បាប់ ហើយក៏ជាផ្នែកដ៏សំខាន់នៃតួនាទី និងការទទួលខុសត្រូវរបស់គណៈមេធាវី។[18]

ដូចដែលគោលការណ៍មូលដ្ឋានរបស់អង្គការសហប្រជាជាតិ និង IBA ស្នើសុំនោះ ការផ្តល់សេវាកម្មច្បាប់ទទួលរ៉ាប់រងដោយមិនគិតថ្លៃឈ្នួល ជាពិសេសអតិថិជនមានប្រាក់ចំណូលទាប គួរតែស្របគ្នា និងជាអចិន្ត្រៃយ៍ ដែលជាផ្នែកមួយនៃគ្រប់គ្រងវិជ្ជាជីវៈច្បាប់រួមបញ្ចូលគ្នា។ ប៉ុន្តែការផ្តល់សេវាកម្មច្បាប់ទទួលរ៉ាប់រងដោយមិនគិតថ្លៃឈ្នួល ជាពិសេសអតិថិជនមានប្រាក់ចំណូលទាប មានសារៈសំខាន់ជាពិសេស ក្នុងពេលមានវិបត្តិ ឬវិវាទ។ ដូចដែលនឹងត្រូវពិភាក្សាបន្ថែមខាងក្រោម កន្លែងណាដែលយុត្តាធិការជួបប្រទះភាពច្របូកច្របល់ គណៈមេធាវីមានតួនាទីសំខាន់ក្នុងការធ្វើឲ្យប្រាកដថា បុគ្គល និងសហគមន៍ទាំងអស់ ហើយជាពិសេសជនក្រីក្រមានឱកាសទទួលបានសេវាកម្មផ្នែកច្បាប់។

## បទបញ្ញត្តិ និងការបណ្តុះបណ្តាល

គណៈមេធាវីដែលមានប្រសិទ្ធភាព ធ្វើឲ្យប្រាកដថា បទបញ្ញត្តិគ្រប់គ្រាន់សម្រាប់អ្នកជំនាញវិជ្ជាជីវៈច្បាប់ ហើយផ្តល់ឱកាសបណ្តុះបណ្តាលដល់មេធាវី និងអ្នកផ្សេងទៀតដែលមានជំនាញវិជ្ជាជីវៈច្បាប់ ដែលរួមមាននិស្សិត និងបុគ្គលដែលបានបណ្តុះបណ្តាលផ្នែកច្បាប់ ប៉ុន្តែមិនមានលក្ខណៈគ្រប់គ្រាន់ជាមេធាវី។ គោលការណ៍មូលដ្ឋានរបស់អង្គការសហប្រជាជាតិ ចែងថា "មេធាវី [គួរតែ] មានកម្រិតវប្បធម៌ និងការបណ្តុះបណ្តាលសមរម្យ ហើយឲ្យដឹងពីគំនិត និងភារៈកិច្ចតាមក្រមសីលធម៌មេធាវី និងសេរីភាពមូលដ្ឋាន ដែលទទួលស្គាល់ដោយច្បាប់

[14] គោលការណ៍មូលដ្ឋាន, paras 1-4.

[15] *Ibid.*

[16] ស្តង់ដារ IBA, *supra* n. 11, para 18(e).

[17] *Ibid.* para 15.

[18] IBA, សេចក្តីប្រកាសអំពីច្បាប់ទទួលរ៉ាប់រងដោយមិនគិតថ្លៃឈ្នួល ជាពិសេសអតិថិជនមានប្រាក់ចំណូលទាបរបស់ IBA, 16 តុលា 2008, paras 1-2. តាមអាសយដ្ឋាន http://www.ibanet.org/Document/Default.aspx?DocumentUid=C4B06FD6-A807-44D4-A98A-C73B464589C6

ជាតិ និងអន្តរជាតិ។"[19] វាទំនងជាមិនអាចបង្កើត ស្តង់ដារអន្តរជាតិសម្រាប់ចូលទៅក្នុងគណៈមេធាវី ដោយសារយុត្តាធិការខុសគ្នាទៅតាមតម្រូវការ និងកម្រិតវប្បធម៌ផ្នែកច្បាប់។ ប៉ុន្តែស្តង់ដារចូល គួរតែបញ្ចូលយ៉ាងហោចណាស់ការអប់រំមុនតម្រូវការ បទពិសោធន៍វិជ្ជាជីវៈ និងការប្រឡង ស្តង់ដារខាងសីលធម៌ និងការធ្វើសម្បថអំពីការប្រព្រឹត្ត។[20] IBA ចែងថា ដោយមិនគិតពីវិធីសាស្រ្តដែលជ្រើសរើស តម្រូវការចូល គួរលើកកម្ពស់ស្តង់ដារខ្ពស់សម្រាប់ការអប់រំផ្នែកច្បាប់ ជាតម្រូវការមូលដ្ឋាន។[21]

បន្ទាប់ពីការអនុញ្ញាតឲ្យចូលក្នុងគណៈមេធាវីហើយ គណៈមេធាវីដែលមានប្រសិទ្ធភាព ធានាថាការសិក្សាបន្តត្រូវតែផ្តល់ជូនទៅសមាជិកនានា។ តម្រូវការសិក្សាផ្នែកច្បាប់បន្ត (CLE) សម្រាប់សមាជិកនៃគណៈមេធាវី គឺមិនគ្រាន់តែជាការអនុវត្តល្អនៅថ្នាក់ជាតិប៉ុណ្ណោះទេ ថែមទាំងជាស្តង់ដារអន្តរជាតិ ដែលតម្រូវឲ្យមានសម្រាប់គណៈមេធាវីទាំងអស់។ IBA បានអះអាងថា ការអប់រំបន្ត "ត្រូវតែជា កាតព្វកិច្ចរបស់សមាជិកម្នាក់ៗនៅក្នុងវិជ្ជាជីវៈច្បាប់"[22] ហើយគណៈមេធាវី និងសង្គមអ្នកច្បាប់ មានការទទួលខុសត្រូវចម្បង ក្នុងការលើកទឹកចិត្តសមាជិករបស់ពួកគេឲ្យចូលរួមការអប់រំបន្ត។[23]

ក្រមសីលធម៌ គឺមានសារៈសំខាន់ស្មើៗគ្នាសម្រាប់គណៈមេធាវី ដើម្បីរក្សាសុចរិតភាពនៃវិជ្ជាជីវៈច្បាប់។ ក្រមទាំងនេះ គួរធ្វើនិយតកម្មទំនាក់ទំនងរវាងមេធាវី និងអតិថិជន មេធាវីផ្សេងទៀត តុលាការ និងសង្គមទាំងមូល។[24] ទីណាដែលមានការប្រព្រឹត្តខុសដោយមេធាវី ស្តង់ដារអន្តរជាតិ ណែនាំថាគណៈមេធាវីត្រូវតែពង្រឹងគោលការណ៍ និងវិធានការនៃការអនុវត្ត។ គោលការណ៍មូលដ្ឋាន របស់អង្គការសហប្រជាជាតិ តម្រូវឲ្យគណៈមេធាវីបង្កើតៈ ក្រមសីលធម៌ នីតិវិធីសមរម្យសម្រាប់ការដាក់ពិន័យពេលមានការរំលោភបំពាន និងយន្តការអនុវត្តពាក់ព័ន្ធ ដើម្បីធានាឲ្យមានការគោរពច្បាប់។[25] IBA បានលើកឡើងជារឿយៗអំពីតម្រូវការទាំងនេះ ដោយបានបន្ថែមថា តួនាទីស្នូលនៃគណៈមេធាវីមួយ គឺត្រូវរក្សា "កិត្តិយស សេចក្តីថ្លៃថ្នូរ សមត្ថភាព សីលធម៌ ស្តង់ដារនៃការប្រព្រឹត្ត និងវិន័យវិជ្ជាជីវៈ។"[26]

[19] គោលការណ៍មូលដ្ឋាន, para 9.

[20] បណ្តាញអន្តរជាតិដើម្បីលើកកម្ពស់ច្បាប់ (INPROL), 'ការបង្កើត និងការធ្វើកំណែទម្រង់គណៈមេធាវី នៅតាមបណ្តារដ្ឋ ក្រោយមានវិវាទ' មករា 2010 នៅទំព័រ p.11

[21] ស្តង់ដារ IBA, *supra* n.11, para 18(h).

[22] គណៈមេធាវីអន្តរជាតិ, 'គោលការណ៍ណែនាំអំពីគោលនយោបាយ IBA សម្រាប់ការបណ្តុះបណ្តាល និងការអប់រំវិជ្ជាជីវៈច្បាប់ (ផ្នែកទី II),' 23 តុលា 2014, para 5.

[23] *Ibid.*, para 2.

[24] INPROL, *supra* n.20 at p.19.

[25] គោលការណ៍មូលដ្ឋាន, paras 16-19.

[26] ស្តង់ដារ IBA, *supra* n. 11 at para 18(b).

គណៈមេធាវីដែលមានប្រសិទ្ធិភាព មានតួនាទីយ៉ាងច្បាស់លាស់ក្នុងការការពារច្បាប់ ទាំងក្នុងយុត្តាធិការ ទាំងនៅថ្នាក់អន្តរជាតិ។ តាមពិតជាការសម្តែងមតិយោបល់អំពីវិជ្ជាជីវៈច្បាប់ គណៈមេធាវីមានការទទួលខុសត្រូវមួយក្នុងការធ្វើឲ្យប្រាកដថា វិធាននៃច្បាប់ត្រូវបានគេគោរព និងគាំទ្រលើកកម្ពស់។ គោលការណ៍មូលដ្ឋានរបស់អង្គការសហប្រជាជាតិ រៀបចំឯកយោងជាច្រើនអំពីតួនាទីរបស់គណៈមេធាវីក្នុងការធានា "ការការពារគ្រប់គ្រាន់លើបញ្ហាសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន ដែលបុគ្គលទាំងអស់ មានសិទ្ធិទទួលបាន" ដោយតម្រូវឲ្យ "បុគ្គលទាំងអស់ បានទទួលសេវាកម្មផ្នែកច្បាប់ប្រកបដោយប្រសិទ្ធភាព ដែលផ្តល់ដោយអ្នកមានវិជ្ជាជីវៈច្បាប់ឯករាជ្យ។"[27] លើសពីនេះ IBA បានអំពាវនាវឲ្យសមាជិករបស់ខ្លួនទាំងអស់ បញ្ចេញមតិ គាំទ្រច្បាប់នៅតាមសហគមន៍របស់ពួកគេ។ ការណ៍នេះតម្រូវឲ្យមានសកម្មភាពដ៏មានប្រសិទ្ធភាពពីខាងគណៈមេធាវី ដើម្បីធ្វើឲ្យប្រាកដថាមានការគោរពច្បាប់ក្នុងយុត្តាធិការ ដែលគេត្រូវធានាឲ្យបានសិទ្ធិមូលដ្ឋាន។

របៀបដែលគណៈមេធាវីធ្វើឲ្យចេញជាការពិតចំពោះការគាំទ្រនេះសម្រាប់វិធាននៃច្បាប់ និងប្រកាន់យកគោលជំហរប្រឆាំងការគំរាមកំហែងនានា ត្រូវបានគេលើកយកមកពិភាក្សាទាំងខាងក្នុង និងជាមួយបណ្តាគណៈមេធាវី។ អាស្រ័យលើការគំរាមកំហែងដែលកំពុងមាន គំនិតផ្តួចផ្តើមក្នុងការលើកកម្ពស់វិធាននៃច្បាប់ អាចត្រូវការចាំបាច់ក្នុងការប្រកាន់យកគោលជំហរសាធារណៈ អំពីបញ្ហាជាក់លាក់ ឬច្បាប់ ឬប៉ះពាល់ដល់គោលនយោបាយរដ្ឋាភិបាលមួយចំនួន។ អ្នកសង្កេតការណ៍ខ្លះ បង្ហាញថា គណៈមេធាវីខ្លះគួរជៀសវាង ការខិតខំប្រឹងប្រែងធ្វើកំណែទម្រង់ច្បាប់ដែលមានភាពចម្រូងចម្រាស់ខ្លាំង ជាពិសេសនៅពេលពួកគេ មិនមានផលប៉ះពាល់ផ្ទាល់មកលើវិជ្ជាជីវៈច្បាប់ ឬទីកន្លែងដែលពួកគេមិនអាចរំពឹងយ៉ាងប្រាកដថានឹងមានឥទ្ធិពលខ្លាំង។[28] ដូច្នេះ គំនិតផ្តួចផ្តើមវិធាននៃច្បាប់ជាច្រើនរបស់គណៈមេធាវី បានផ្តោតលើការងារនៅក្នុងយុត្តាធិការដទៃ ជាជាងការអភិវឌ្ឍវិធាននៃច្បាប់ "នៅក្នុងប្រទេស"។ ឧទាហរណ៍គំនិតផ្តួចផ្តើមច្បាប់របស់ ABA (ROLI) បានធ្វើការនៅក្នុងប្រទេសជាង 90 ដើម្បីពង្រឹងសមត្ថភាពរបស់គណៈមេធាវី ដើម្បីឲ្យចូលប្រឡូកក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីផលប្រយោជន៍

[27] គោលការណ៍មូលដ្ឋាន, កថាខណ្ឌទី 9, បុព្វកថា
[28] Johnstone, *supra n.1* at 240.

សាធារណៈ ដោះស្រាយបញ្ហានានា ដែលទាក់ទងនឹងឯករាជ្យភាពនៃវិជ្ជាជីវៈច្បាប់ និងធ្វើការដោះស្រាយបញ្ហាសិទ្ធិមនុស្ស។[29]

បន្ថែមលើស្តង់ដារអន្តរជាតិ ការអនុវត្តល្អថ្នាក់ជាតិ ផ្តល់ការណែនាំបន្ថែមអំពីបេសកកម្ម និងអាណត្តិ ការគ្រប់គ្រង និងរចនាសម្ព័ន្ធ និងកម្មវិធី។ ជាការពិត នៅតាមបណ្តាយុត្តាធិការ មានទាំងចំណុចរួម និងចំណុចខុសគ្នាទៅតាមលក្ខណៈគណៈមេធាវី ដែលផ្តល់លទ្ធភាពឲ្យពួកគេអនុវត្តតួនាទីរបស់ខ្លួន។ ផ្នែកបន្ទាប់ ពិនិត្យមើលអំពីអាណត្តិ ការគ្រប់គ្រង និងកម្មវិធីគណៈមេធាវីថ្នាក់ជាតិផ្សេងៗ ដើម្បីបែងចែកឲ្យដាច់នូវលក្ខណៈវិនិច្ឆ័យ និងស្តង់ដារប្រសិទ្ធភាពបន្ថែម។

[29] សូមមើល J. Rasmussen, 'ប្រវត្តិសង្ខេបអំពីវិធីសាស្ត្រកជំនួយបច្ចេកទេសរបស់គំនិតផ្តួចផ្តើមនៃច្បាប់គណៈមេធាវីអាមេរិកាំង' Wisconsin Int'l L. J. 31(3), 2013.

# II. ស្តង់ដារជាតិ

បេសកកម្ម ឬអាណត្តិរបស់គណៈមេធាវី បង្កើតបានជាមូលដ្ឋានគ្រឹះដ៏សំខាន់ ដែលមានស្តង់ដារ និងគោលបំណងដែលគេរំពឹងទុករបស់អង្គការចាត់តាំង ហើយជាមាគ៌ាសម្រាប់អង្គការចាត់តាំងក្នុងការអនុវត្តសកម្មភាពនានា។ ការចាត់ចែង និងដឹកនាំរបស់គណៈមេធាវីនៅក្នុងយុត្តាធិការផ្សេងៗ ក៏បង្ហាញអំពីតម្រូវការចនាសម្ព័ន្ធដ៏សំខាន់ចំពោះមុខងារដ៏មានប្រសិទ្ធភាពរបស់គណៈមេធាវី។ ចុងបញ្ចប់កម្មវិធី និងសកម្មភាពគោលដៅរបស់គណៈមេធាវីបង្ហាញពីគំរូប្រសិទ្ធភាព ហើយក៏បង្ហាញពីកម្រិតអនុវត្តសកម្មភាព មានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមកជាមួយអាណត្តិ និងអំណះអំណាងបេសកកម្ម។

## បេសកកម្ម និងអាណត្តិ

បេសកកម្មរបស់គណៈមេធាវី ពង្រឹងការគ្រប់គ្រង និងកម្មវិធីរបស់វា ហើយជួយអង្គការចាត់តាំង លើកការកំណត់អាទិភាពសកម្មភាពរបស់ខ្លួន។ ដូចឃើញក្នុងឧទាហរណ៍ខាងក្រោម គណៈមេធាវីភាគច្រើន មានអាណត្តិស្រដៀងគ្នា ហើយត្រូវបានគេបង្កើតឡើងតាមគោលការណ៍ដែលពាក់ព័ន្ធ។ ជាទូទៅគណៈមេធាវី ត្រូវបានគេរៀបចំចាត់ចែងឲ្យក្លាយជាការសម្តែងមតិយោបល់វិជ្ជាជីវៈច្បាប់នៅក្នុងយុត្តាធិការ។ គណៈមេធាវីចាំបាច់ ឬពេញលេញនៅថ្នាក់ជាតិ ឬថ្នាក់រដ្ឋ ដឹកនាំដោយបេសកកម្មច្រើន ដែលសង្កត់ធ្ងន់លើច្បាប់ បញ្ញត្តិនៃវិជ្ជាជីវៈច្បាប់ ក្រមសីលធម៌ និងវិជ្ជាជីវៈ។ ជាញឹកញាប់បេសកកម្មទាំងនេះ ផ្តោតលើបញ្ហា ដូចជាការកាត់បន្ថយការលំអៀង និង ការរើសអើងក្នុងវិជ្ជាជីវៈ ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ឬឱកាសតាមបណ្តាញជាន់ខ្ពស់សម្រាប់មេធាវីខាងជំនាញច្បាប់ដូចគ្នា។[30]

ឧទាហរណ៍គណៈមេធាវីអាមេរិកាំង (ABA) ដែលជាគណៈមេធាវីស្ម័គ្រចិត្តដ៏ធំបំផុតមួយក្នុងចំណោមគណៈមេធាវីជាច្រើន ដែលមាននៅលើពិភពលោក មានគោលបំណងរបស់ខ្លួន ក្នុងការៈ បម្រើសមាជិករបស់ខ្លួនតាមរយៈឱកាសអភិវឌ្ឍអាជីព ធ្វើឲ្យប្រសើរឡើងនូវវិជ្ជាជីវៈច្បាប់តាមរយៈការអប់រំច្បាប់ ក្រមសីលធម៌ និងសេវាកម្មសាធារណៈ កាត់បន្ថយភាពលំអៀង និងលើកកម្ពស់ភាពផ្សេងគ្នាក្នុងវិជ្ជាជីវៈច្បាប់ និងប្រព័ន្ធយុត្តិធម៌ ហើយធ្វើឲ្យមានភាពជឿនលឿនវិធានច្បាប់នៅទូទាំងពិភពលោក។ [31] ស្រដៀងគ្នាដែរ ក្រុមប្រឹក្សាមេធាវីចក្រភព

---

[30] E. Chambliss and B. Green, 'តថភាពអំពីគណៈមេធាវី' *Depaul Law Review*, 57(2), 2008, p. 425; *សូមមើលផងដែរ*, សង្គមអ្នកច្បាប់របស់សភាកាណាដា, 'ការសិក្សាអំពីសង្គមអ្នកច្បាប់ និងការស្វែងរក ការអនុវត្តន៍ដ៏ល្អបំផុត' តុលា 30, 2014, p.27.
[31] គណៈមេធាវីអាមេរិកាំង, សៀវភៅណែនាំអំពីគោលនយោបាយ និងនីតិវិធី 2014-2015, pp.1-2 មាននៅលើវិបសាយថ៍ http://www.americanbar.org/content/dam/aba/administrative/ house_of_delegates/2014-2015_policy_and_procedures_handbook_greenbook1. authcheckdam. pdf

អង់គ្លេស មានបេសកកម្មរបស់ខ្លួនក្នុងការៈ លើកកម្ពស់សេវាកម្មគណៈមេធាវី លើកកម្ពស់ការទទួលបានយុត្តិធម៌ លើកកម្ពស់ក្រមសីលធម៌ ស្មើភាពគ្នា និងភាពទីទៃពីគ្នាក្នុងវិជ្ជាជីវៈ និងលើកកម្ពស់បណ្ដាញមេធាវីអង់គ្លេសក្នុងស្រុក និងនៅក្រៅប្រទេស។[32] អគ្គគណៈមេធាវីអាហ្វ្រិកខាងត្បូង ខិតខំដើម្បីៈ ការបង្រៀន និងការប្រកបវិជ្ជាជីវៈច្បាប់ និងការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌ ដោះស្រាយនឹងបញ្ហាគ្រប់ជំពូកដែលមានសម្រាប់វិជ្ជាជីវៈច្បាប់ ហើយចាត់វិធានការចំពោះបញ្ហាដែលពាក់ព័ន្ធ ហើយលើកស្ទួយផលប្រយោជន៍របស់មេធាវីនៅអាហ្វ្រិកខាងត្បូង។ [33] បើទោះជាមានយុត្តាធិការផ្សេងគ្នានៅក្នុងមុខងាររបស់គណៈមេធាវីក៏ដោយ ក៏នៅមានអាណត្តិស្ទួលទូទៅរបស់គណៈមេធាវី ទាំងក្នុងប្រពៃណីនៃច្បាប់រួម និងច្បាប់រដ្ឋប្បវេណី។ ជាឧទាហរណ៍នៃវិសាលភាពគ្របដណ្ដប់ គណៈមេធាវីនីមួយៗនៅ ដើម៉ែកា បារាំង ហុងកុង កេនយ៉ា ណាមិបៀ និងអ៊ីស្រាអែល មានអំណះអំណាងបេសកកម្ម ឬកម្មវត្ថុ ដែលទាក់ទងនឹងសុចរិតភាពនៃ វិជ្ជាជីវៈច្បាប់ និងក្រមសីលធម៌ អប់រំសាធារណៈសម្រាប់មេធាវី និងការជួយដល់ផលប្រយោជន៍ សាធារណៈតាមរយៈគំនិតផ្ដួចផ្ដើមជំនួយផ្នែកច្បាប់ និងការធ្វើឲ្យជឿនលឿនលើច្បាប់។[34] គណៈមេធាវីថ្នាក់ជាតិ ពេញលេញ ឬដែលគ្រប់ដណ្ដប់ទាំងនេះ មានតួនាទីសំខាន់ក្នុងការធ្វើនិយតកម្មវិជ្ជាជីវៈច្បាប់ ការធានាក្រមសីលធម៌ និងការលើកកម្ពស់វិធាននៃច្បាប់ជាទូទៅ។ ឧទាហរណ៍គណៈមេធាវីជំនាញ ដូចជាគណៈមេធាវីអេស្ប៉ាញនៅសហរដ្ឋអាមេរិក គណៈមេធាវីជនជាតិដើមនៅកាណាដា និងគណៈមេធាវីច្បាប់គ្រួសារ នៅចក្រភពអង់គ្លេស ជាញឹកញាប់មានបេសកកម្មជាក់លាក់ ដែលផ្ដោតលើវិស័យច្បាប់ណាមួយ ក្រុមមេធាវីណាមួយដែលមានលក្ខណៈរួម ឬលើបុព្វហេតុសង្គម និងច្បាប់។

## ការរៀបចំ និងរចនាសម្ព័ន្ធគណៈមេធាវី

ការរៀបចំគណៈមេធាវី ទទួលរងផលប៉ះពាល់ពីគោលការណ៍ដឹកនាំ ឬអាណត្តិរបស់វា រចនាសម្ព័ន្ធ នៃការដឹកនាំភាពទីទៃពីគ្នានៃគណៈមេធាវី និងគណៈកម្មការ និងផ្នែកផ្សេងៗ។ ការរៀបចំត្រឹមត្រូវនៃគណៈមេធាវី គឺសំខាន់

[32] ក្រុមប្រឹក្សាគណៈមេធាវីចក្រភពអង់គ្លេស អំណះអំណាងបេសកកម្ម មាននៅលើវិបសាយថ៍ http://www.barcouncil.org.uk/about-us/mission-statement/, បានចូលប្រើនៅថ្ងៃ 30 ខែតុលា ឆ្នាំ 2015។

[33] វិបសាយថ៍អគ្គគណៈមេធាវីអាហ្វ្រិកខាងត្បូង, អំណះអំណាងបេសកកម្ម, មាននៅលើវិបសាយថ៍ http://www.sabar.co.za/about.html ចូលទៅមើលនៅថ្ងៃទី 30 តុលា 2015។

[34] *សូមមើល,* ឧទាហរណ៍, គណៈមេធាវីជើម៉ែកា, 'អំពី JamBar,' < http://www.jambar.org/index.php?option=com_content&view=article&id=2&Itemid=214>; គណៈមេធាវីអ៊ីស្រាអែល, 'មុខងារដែលមានចែងក្នុងលក្ខន្តិកៈ,' 31 សីហា 2015 < http://www.israelbar.org.il/english_inner.asp?pgId=103336&catId=372>; សង្គមមេធាវី ណាមីបៀ, 'កម្មវត្ថុនៃសង្គមមេធាវីណាមីបៀ' < http://www.namibianbar.org/About.htm>; សង្គមអ្នកច្បាប់ កេនយ៉ា 'កម្មវត្ថុ' 2016, < http://www.lsk.or.ke/index.php/about-lsk>; សង្គមអ្នកច្បាប់ ហុងកុង 'ប្រវត្តិ' មេសា 2015 < http://www.hklawsoc.org.hk/pub_e/about/>; Conseil National des Barreaux de la France, 'បេសកកម្ម' 10 មករា 2012, < http://cnb.avocat.fr/Missions-du-Conseil-National-des-Barreaux_a35.html>

សម្រាប់មុខនាទីសកម្មភាព និងកម្មវិធី។ តាមពិត ការរៀបចំមិនបានល្អ នាំឲ្យមានសំណល់ និងគ្មានប្រសិទ្ធភាព ប៉ុន្តែថែមទាំងបង្កើនលទ្ធភាពនៃការមិនយល់ស្របផ្ទៃក្នុងផងដែរ ដោយត្រូវលះបង់ប្រសិទ្ធភាពចោលថែមទៀត។[35]

ជាធម្មតាគណៈមេធាវីជាច្រើន ធ្វើតាមរចនាសម្ព័ន្ធអង្គការលេខស្រដៀងគ្នា ដែលមានសមាជិក មិនមានប្រាក់ខែ ធ្វើការក្រៅម៉ោង ក្នុងតំណែងថ្នាក់ដឹកនាំគណៈកម្មការនានា ដែលផ្តោតលើបញ្ហាជាក់លាក់ និងសមាជិកដែលមានប្រាក់ខែក្នុងចំនួនតិច។ ភាគច្រើននៃសកម្មភាពទាំងនេះ ត្រូវត្រួតពិនិត្យដោយគណៈកម្មការ និងផ្នែកដែលដំណើរការដោយឯករាជ្យ ហើយដោះស្រាយបញ្ហាផ្សេងៗ និងវិស័យនានានៃច្បាប់។ Johnstone បានលើកទឡ្ហីករណ៍ថា ខណៈដែលថ្នាក់ដឹកនាំកំពូល នៅតែតាមការត្រួតពិនិត្យខ្លះលើសកម្មភាព និងជាញឹកញាប់តែងតាំងសមាជិកក្នុងផ្នែក និងគណៈកម្មការខ្លះ ជាទូទៅការដឹកនាំនោះ គឺដោយស្ម័គ្រចិត្ត និងពិធីការជាងដោយប្រើអំណាច។ គាត់បន្ថែមទៀតថា ជាញឹកញាប់ទង្វើនេះតែងនាំទៅរកការដឹកនាំថ្នាក់កណ្តាលមួយដ៏ទន់ជ្រាយ ដោយខ្វះការសម្របសម្រួលរវាងគណៈកម្មការ និងផ្នែកដែលនាំឲ្យមានការខិតខំប្រឹងប្រែងជាន់គ្នា។[36] ដូច្នេះ ប្រសិទ្ធភាពនៅក្នុងគណៈមេធាវីណាក៏ដោយ អាចកែលម្អឲ្យប្រសើរឡើង ទីណាមានការដឹកនាំថ្នាក់កណ្តាលខ្លាំងជាង ហើយការសម្របសម្រួលរឹងមាំជាងរវាងគណៈកម្មការ និងផ្នែកដែលត្រួតពិនិត្យការរៀបចំកម្មវិធី។

ភាពទីទៃនៅក្នុងការដឹកនាំ និងសមាជិកភាពជារួម ក្លាយជាបញ្ហាសំខាន់នៅក្នុងការរៀបចំគណៈមេធាវីនានា។ ដោយសារគណៈមេធាវីជាច្រើន បញ្ចូលបេសកកម្មរបស់ពួកគេទៅលើការកាត់បន្ថយភាពលំអៀង និងការរើសអើងក្នុងវិជ្ជាជីវៈច្បាប់ គណៈមេធាវីភាគច្រើនមានលក្ខខណ្ឌខាងរចនាសម្ព័ន្ធនៃ ការដាក់បញ្ចូលគ្នា និងភាពទីទៃពីគ្នា។ ឧទាហរណ៍សង្គមអ្នកច្បាប់របស់សភាជាន់ខ្ពស់កាណាដា បញ្ជាក់ថា "គណៈមេធាវីមានគោលជំហរច្បាស់លាស់ ក្នុងការធ្វើឲ្យមានឥទ្ធិពលទៅលើភាពទីទៃពីគ្នា ដោយធ្វើជាគំរូឲ្យបណ្តាក្រុមហ៊ុន អង្គការ និងបុគ្គលនានាធ្វើតាម។[37] ABA មានគំនិតផ្តួចផ្តើមភាពទីទៃជាប្រធាន (Presidential Diversity Initiative) ដែលបង្កើតកម្មវិធីជាក់លាក់ និងគម្រោងទីទៃនានា ដើម្បីធានាឲ្យមានការបញ្ចូលក្រុមភាគតិចផ្សេងៗក្នុងវិជ្ជាជីវៈ

---

[35] Johnstone, *supra* n.1 at p.199.

[36] *Ibid.* p.205.

[37] សង្គមអ្នកច្បាប់របស់សភាជាន់ខ្ពស់កាណាដា 'ការសិក្សាអំពីសង្គមអ្នកច្បាប់ និងការស្វែងរកការអនុវត្តន៍ល្អបំផុត' នាយកដ្ឋានគំនិតផ្តួចផ្តើមសមភាព, តុលា 30, 2014, p.27. តាមអាសយដ្ឋាន http://www.lsuc.on.ca/uploadedFiles/Equity_and_Diversity/Members/Challenges_for_Racialized_Licensees/law-society-studies-and-scan-of-best-practices-racialized-licensees-working-group.pdf

ច្បាប់។[38] គណៈមេធាវីអៀរឡង់ខាងជើង មានគោលនយោបាយភាពទីទៃផ្លូវការ និងក្រុមប្រឹក្សាគណៈមេធាវីចក្រភពអង់គ្លេស មានគណៈកម្មការទទួលបន្ទុកភាពស្មើគ្នា ភាពទីទៃពីគ្នា និងការប្រមូលផ្តុំផ្នែកសង្គម។[39]

តួនាទីយេនឌ័រ មានសារៈសំខាន់ចំពោះមុខនាទីដ៏មានប្រសិទ្ធភាព និងដោយសមធម៌របស់គណៈមេធាវី។ ការណ៍នេះ ទាមទារឲ្យមានការដាក់បញ្ចូលទាំងមេធាវីជាបុរស និងជាស្ត្រីនៅក្នុងការរៀបចំ និងការធ្វើរចនាសម្ព័ន្ធគណៈមេធាវី ព្រមទាំងការលើកកម្ពស់សមភាពយេនឌ័រទាំងខាងក្នុង និងខាងក្រៅ។ គណៈមេធាវីអាហ្វហ្គានីស្ថានឯករាជ្យ មានកូតាសម្រាប់ស្ត្រីក្នុងតួនាទីដឹកនាំ និងគណៈកម្មការនានា។[40] គណៈមេធាវីអាមេរិកាំង បានបង្កើតគណៈកម្មាធិការមួយសម្រាប់ស្ត្រីផ្នែកវិជ្ជាជីវៈ ដើម្បីបម្រើការជាសម្លេងមតិយោបល់ថ្នាក់ជាតិសម្រាប់មេធាវីស្ត្រី និងដើម្បីធានាឲ្យមានឱកាសស្មើគ្នាសម្រាប់អ្នកជំនាញច្បាប់ទាំងបុរស និងស្ត្រី។[41] តាមពិតគណៈមេធាវីដ៏មានប្រសិទ្ធភាព ខិតខំឲ្យអ្នកជំនាញច្បាប់ចូលរួមយ៉ាងសកម្មនៅគ្រប់ស្រទាប់សង្គម ដើម្បីលុបបំបាត់ចោលអំពើលំអៀងក្នុងប្រព័ន្ធយុត្តិធម៌ និងដើម្បីលើកកម្ពស់ការចូលរួមដោយស្មើភាពគ្នា។

## ការរៀបចំកម្មវិធី

កម្មវិធី និងសកម្មភាពនានារបស់គណៈមេធាវី ផុសចេញពីបេសកកម្ម និងអាណត្តិរបស់ពួកគេ ហើយអាចមានលក្ខណៈផ្សេងពីគ្នាដូចយុត្តាធិការ ដែលគណៈមេធាវីនោះដំណើរការ។ ដូចបាន បង្ហាញខាងលើ គណៈមេធាវីជាច្រើនមានសមាសធាតុអាណត្តិស្នូលស្រដៀងគ្នា ដែលនាំឲ្យមានកម្មវិធីស្របគ្នា ដែលដោះស្រាយតម្រូវការសម្រាប់ការអប់រំបន្តផ្នែកច្បាប់ ក្រមសីលធម៌វិជ្ជាជីវៈ និងការដាក់វិន័យ និងកម្មវិធីដែលពាក់ព័ន្ធនឹងកំណែទម្រង់ច្បាប់។ កម្មវិធីទាំងនេះ នឹងត្រូវបានគេវិភាគ ដើម្បីរកឲ្យឃើញលក្ខណៈវិនិច្ឆ័យចំពោះប្រសិទ្ធភាព។

ការអប់រំបន្តផ្នែកច្បាប់ (CLE) គឺចាំបាច់ចំពោះគណៈមេធាវីដែលមានប្រសិទ្ធភាព ហើយបំពេញ បេសកកម្មរួមដើម្បីចូលរួមក្នុងការអភិវឌ្ឍន៍វិជ្ជាជីវៈសម្រាប់មេធាវី។ តាមពិត CLE បានបញ្ជាក់ថាជា កម្មវិធីដ៏សំខាន់របស់

[38] សូមមើល ABA Presidential Diversity Initiative, ‵ភាពទីទៃពីគ្នា ក្នុងវិជ្ជាជីវៈច្បាប់៖ ជំហានបន្ទាប់′ មេសា 2010។

[39] វិបសាយថ៍របស់គណៈមេធាវីចក្រភពអង់គ្លេស, ‵E&D និងការប្រមូលផ្តុំផ្នែកសង្គម,′ ចូលមើលនៅថ្ងៃ 30 តុលា 2015។

[40] បណ្តាញអន្តរជាតិសម្រាប់ការលើកកម្ពស់ច្បាប់ (INPROL), ‵ការបង្កើត និងកំណែទម្រង់គណៈមេធាវី ក្នុងបណ្តារដ្ឋ ក្រោយមានវិវាទ′ មករា 2010, p.10

[41] គណៈមេធាវីអាមេរិកាំង, ‵ស្ត្រីក្នុងវិជ្ជាជីវៈ′ 2015, មាននៅលើវិបសាយថ៍ http://www.americanbar.org/groups/women.html

គណៈមេធាវី នៅទូទាំងពិភពលោក។ វគ្គសិក្សា CLE គួរតែទាក់ទង និងមានប្រយោជន៍សម្រាប់ទស្សនិកជនទាំងអស់ ដែលរួមមានមេធាវីចូលរួមតាមរដូវកាល។[42] លើសពីនេះ គណៈមេធាវីគួរតែខិតខំជួយដល់សាលានីតិសាស្ត្រ ដើម្បីឲ្យឥទ្ធិពលដល់ការអប់រំផ្នែកច្បាប់ សម្រាប់មេធាវីម្នាក់ៗ។[43] គណៈមេធាវីខ្លះ មកពីយុត្តាធិការធំៗ ដែលមានជំនួយហិរញ្ញវត្ថុសំខាន់ៗ អាចផ្តល់កម្មវិធីសិក្សាអនឡាញឬតាមបណ្តាញអេឡិកត្រូនិក ឬកម្មវិធីសិក្សាពីចម្ងាយ ខណៈដែលគណៈមេធាវីដទៃទៀត សម្របតាមកាលៈទេសៈ និងធនធានក្នុងស្រុក។

ក្រមសីលធម៌វិជ្ជាជីវៈ មានសារៈសំខាន់សម្រាប់គណៈមេធាវី ក្នុងការធ្វើនិយតកម្មផ្ទាល់ខ្លួនអំពីឥរិយាបថរបស់មេធាវី និងដាក់ពិន័យលើការប្រព្រឹត្តខុស ដើម្បីរក្សាភាពសុចរិត និងកេរ្តិ៍ឈ្មោះនៃវិជ្ជាជីវៈច្បាប់ក្នុងយុត្តាធិការនោះ។[44] ក្នុងសហរដ្ឋអាមេរិក Devlin យល់ឃើញថា យុត្តាធិការទាំងអស់ បានចែងថាការដាក់ទោសទណ្ឌ គឺមិនមែនជាគោលបំណងរបស់សវនាការដាក់ពិន័យ ប៉ុន្តែវាមានគោលបំណង ដើម្បីការពារសាធារណៈជន និងវិជ្ជាជីវៈពីការអនុវត្តខុស ប៉ុន្តែការពារការប្រព្រឹត្តខុសស្រដៀងគ្នាពីមេធាវីដទៃទៀត។[45] ដើម្បីឲ្យមានប្រសិទ្ធភាព ត្រូវតែមានយន្តការមួយដើម្បីអនុវត្តវិធានការដាក់ពិន័យ និងធានាការគោរពនិងការអនុវត្ត។ វិធាន និងនិតិវិធីដាក់ពិន័យផ្សេងទៀត តាមបណ្តាយុត្តាធិការ គឺមិនអាចជៀសវាងបានទេ ដោយសារលទ្ធផលនៃវប្បធម៌ និងបរិយាកាសច្បាប់ខុសគ្នា។ នៅកន្លែងណាដែលសមាជិកភាពក្នុងគណៈមេធាវី មិនមានការតម្រូវចាំបាច់ ដូចជាគណៈមេធាវី ឯករាជ្យម៉ិកស៊ិកូ ត្រេប៊ីឡុក (Trebilock) និង ដានីអែល (Daniels) លើកទឡ្ហីករណ៍ថា គ្មានយន្តការក្នុងការអនុវត្តបទបញ្ញត្តិឡើយ។[46] បើទោះជានៅកន្លែងណាដែលសមាជិកភាពរបស់គណៈមេធាវី មានតម្រូវការចាំបាច់ ហើយគណៈមេធាវីទាំងនោះ មានការទទួលខុសត្រូវក្នុងការធ្វើនិយតកម្មគុណភាពរបស់មេធាវី យន្តការដាក់ពិន័យ ដែលជាញឹកញាប់បង្ហាញថាគ្មានលក្ខណៈគ្រប់គ្រាន់ក្នុងការអនុវត្តន៍។[47] ក្នុងយុត្តាធិការខ្លះ ដូចជា ប្រទេសអាក្វាឌ័រ ត្រេប៊ីឡុក (Trebilock) និងដានីអែល (Daniels) លើកទឡ្ហីករណ៍ថា ការដាក់ទណ្ឌកម្ម

---

[42] Johnstone, *supra* n.1 at p.210, 236.

[43] *Ibid.* at p.208.

[44] *សូមមើល*, ឧទាហរណ៍, អគ្គគណៈមេធាវីអាហ្វ្រិកខាងត្បូត, 'វិធានប្រតិបត្តិវិជ្ជាជីវៈរួម,' អាសយដ្ឋានវិបសាយថ៍ http://www.sabar.co.za/GCB-UniformRules-of-Ethics-updated-July2012.pdf; គណៈមេធាវី កូសូវ៉ូ, 'ក្រមសីលធម៌វិជ្ជាជីវៈមេធាវី,' 01 ធ្នូ 2012, អាសយដ្ឋានវិបសាយថ៍ http://www.oak-ks.org/repository/docs/Code_of_Ethics_2012_(ENG)_(update_January_2014)_638576.pdf; គណៈមេធាវីឥណ្ឌា, 'វិធាននៃគណៈមេធាវីឥណ្ឌា,' ធ្វើវិសោធនកម្មថ្ងៃ 30 កញ្ញា 2009, អាសយដ្ឋាន http://www.barcouncilofindia.org/wp-content/uploads/2010/05/BCIRulesPartItoIII.pdf

[45] Mary Devlin, 'ការបង្កើតនីតិវិធីដាក់វិន័យមេធាវី នៅសហរដ្ឋអាមេរិក', *Georgetown Journal of Legal Ethics,* Spring 1994, p.385

[46] M. Trebilock និង R. Daniels, *កំណែទម្រង់ និងអភិវឌ្ឍច្បាប់៖ : គំនូរតាងមាគ៌ាប្រេះស្រាំនៃវឌ្ឍនភាព* (Edward Elgar Publishing: 2009), p.320

[47] *Ibid.* p.321.

ចំពោះការរំលោភបំពាន មានចាប់ពីការព្រមានរហូតដល់ការបង់ថ្លៃឈ្នួលតិចតួច។[48] ក្នុងបណ្ដាប្រទេសដទៃទៀត ដូចជាអាហ្វ្រិកខាងត្បូង សមាជិកភាព គឺតម្រូវជាចាំបាច់នៅកម្រិតថ្នាក់ជាតិ ប៉ុន្តែគណៈមេធាវីតំបន់ ត្រួតពិនិត្យការប្រកាន់ខ្ជាប់ទៅនឹងស្តង់ដារថ្នាក់ជាតិ ដែលនាំឲ្យមានភាពខុសគ្នាលើបទបញ្ញត្តិអំពីការប្រព្រឹត្តរវាងថ្នាក់តំបន់ អាស្រ័យទៅលើប្រសិទ្ធភាពនៃគណៈមេធាវីតំបន់។[49]

ទម្រង់នានានៃការដាក់ទណ្ឌកម្មដែលខ្លាំងជាងនេះ រាប់ទាំងការបញ្ឈប់បណ្ដោះអាសន្ន និងការដកហូតវិជ្ជាជីវៈមេធាវីដែលអាចមានចំពោះបទល្មើសធ្ងន់ធ្ងរបំផុត បើទោះជាភាពញឹកញាប់នៃការប្រើប្រាស់របស់ពួកគេ គឺពិបាកវាស់ស្ទង់ក៏ដោយ ឬមិនអាចមានអាជ្ញាធរដាក់ពិន័យក្នុងគណៈមេធាវី។ នៅក្នុងយុត្តាធិការផ្សេងៗ វិធានការដាក់ពិន័យមានខុសគ្នាជាច្រើន ហើយជាញឹកញាប់ផ្លាស់ប្តូរនៅពេលគណៈមេធាវីមានការរីកចម្រើន។ ឧទាហរណ៍ គណៈមេធាវីព័រទុយហ្គាល់ ពីដើមត្រូវបានគេឃើញថា មានលក្ខណៈអាណិតអាសូរ ទាក់ទងនឹង "អំពើបាបកម្ម" របស់មេធាវី។ ប៉ុន្តែនៅពេលដែលគណៈមេធាវីមានការធំធាត់ មានសមាជិកភាពច្រើន នីតិវិធីដាក់ពិន័យ ក៏បានលេចចេញរូបរាងឡើងជាផ្លូវការ ដោយមានការព្រមានជាលាយលក្ខណ៍អក្សកើនឡើងមួយជាដប់ ការផាកពិន័យកើនឡើងមួយជាសាមសិប ហើយការបញ្ឈប់បណ្ដោះអាសន្នចំពោះវិជ្ជាជីវៈកើនឡើងមួយជាសែសិប។[50] ដូចកត់ចំណាំខាងលើ ក្នុងយុត្តាធិការដទៃ គណៈមេធាវីត្រូវបានគេកំណត់ ឬហាមឃាត់ពីការអនុវត្តវិធានការវិន័យចំពោះមេធាវី។ នៅប្រទេសនីហ្សេរីយ៉ា បើទោះជាគណៈមេធាវីធ្វើនិយតកម្មដោយខ្លួនឯងក៏ដោយ ក៏វិធានការដាក់ពិន័យត្រូវបានអនុវត្តដោយតុលាការផងដែរ។[51] នៅហុងកុង Dikes លើកឡើងថា តុលាការពិន័យក្នុងគណៈមេធាវី មានសិទ្ធិអំណាចក្នុងការជំទាស់ ព្យួរការងារ លុបចោល បង្គាប់បញ្ជាឲ្យបង់ប្រាក់ និងចេញថ្លៃចំណាយ។[52] Devlin ណែនាំថា គណៈមេធាវី គួរដើរតួនាទីស្តារ បង្ការ និងរកដំណោះស្រាយ ដើម្បីការពារប្រព័ន្ធច្បាប់ ជាជាងដាក់ពិន័យដល់មេធាវី ដែលគេបញ្ជូនទៅការពារក្តីក្នុងតុលាការ។[53] ប៉ុន្តែគណៈមេធាវី មានតួនាទីសំខាន់មួយក្នុងការធានាថា វិធានការវិន័យនៅតែជាអាទិភាពដើម្បីធានាភាពសុចរិតនៃវិជ្ជាជីវៈច្បាប់ ហើយនៅតែស្របជាមួយនឹងអាណត្តិនីមួយៗ។

នៅចុងបញ្ចប់គណៈមេធាវីដែលមានប្រសិទ្ធភាព គឺត្រូវសកម្ម ហើយមានឥទ្ធិពលនៅក្នុងកំណែទម្រង់ ច្បាប់

---

[48] *Ibid.*

[49] *Ibid.* p.324.

[50] Jose Miguel Judice, វិធានការវិន័យរបស់គណៈមេធាវីព័រទុយហ្គាល់, និក្ខេបទ ដែលគេបង្ហាញនៅក្រុមប្រឹក្សា IBA ពាក់កណ្ដាលឆ្នាំ ទីក្រុង Lisbon, ឧសភា 2005។

[51] IBA, ‵គណៈមេធាវី – វិន័យ និងច្បាប់′, សម័យប្រជុំតំណាងគណៈមេធាវី
, ទីក្រុង Lisbon ប្រទេស ព័រទុយហ្គាល់, 19 ឧសភា 2005។ មាននៅលើវិបសាយថ៍
http://www.ibanet.org/barassociations/bar_associations_disciplinary_measures.aspx

[52] Philip Dikes, វិន័យ និងគណៈមេធាវី ហុងកុង, និក្ខេបទ ដែលគេបង្ហាញនៅ IBA ពាក់កណ្ដាលឆ្នាំ ទីក្រុង Lisbon, ឧសភា 2005។

[53] Mary Devlin, ‵ការអភិវឌ្ឍន៍នីតិវិធីដាក់វិន័យមេធាវី នៅសហរដ្ឋអាមេរិក′, *Georgetown Journal of Legal Ethics,* Spring 1994, p.387.

ជាញឹកញាប់តាមទម្លាប់គណៈកម្មការផ្សេងៗ។ ឧទាហរណ៍គណៈមេធាវីរដ្ឋ New South Wales មានគណៈកម្មការច្បាប់ព្រហ្មទណ្ឌ ដែលសកម្មលើកំណែទម្រង់គោលនយោបាយគ្រឿង ញៀននៅប្រទេសអូស្ត្រាលី។ គណៈមេធាវីកាណាដា មានគណៈកម្មការជាច្រើន ដែលធ្វើការតែទៅ លើផ្នែកច្បាប់ និងកំណែទម្រង់ច្បាប់។[54] គណៈមេធាវីជាច្រើន អាចវាយតម្លៃច្បាប់នានា មុនអង្គនីតិបញ្ញត្តិ ហើយអាចប្រកាន់យកគោលជំហរសាធារណៈ។[55] ជាងនេះទៅទៀត គណៈមេធាវីអាចបញ្ចុះបញ្ចូលអ្នកតាក់តែងច្បាប់ម្នាក់ៗ សម្រាប់កំណែទម្រង់ច្បាប់ ដែលស្របនឹងអាទិភាពរបស់គណៈមេធាវី និងច្បាប់។[56] ភាពតានតឹងទាំងនេះ ត្រូវបានគេកត់ចំណាំជាញឹកញាប់បំផុត ក្នុងបរិបទនៃភាពច្របូកច្របល់ និងវិបត្តិសង្គម។

ចំពោះស្ថានភាពមានវិបត្តិ តួនាទីរបស់គណៈមេធាវី ជាញឹកញាប់មានលក្ខណៈចំរូងចំរាស់ និងផុយស្រួយខ្លាំង។ ជាពិសេសក្នុងយុត្តាធិការ ដែលសមាជិកភាព មានតម្រូវការចាំបាច់ សមាជិក ម្នាក់ៗ អាចនាំយកបញ្ហាដោយឲ្យគណៈមេធាវីតតាំងជំនួស ជាពិសេសនៅពេលពួកគេមិនយល់ស្របទៅនឹងគោលជំហររួម។ [57] អ្នកដទៃទៀតលើកឡើងថា ជ្រុងដែលតភ្ជាប់រវាងច្បាប់ និងនយោបាយ គឺជាជ្រុងមួយដែលមេធាវីមានភារកិច្ចនិយាយ ហើយប្រកាន់ជំហរមួយចំពោះបញ្ហា ដែលចំរូងចំរាស់។[58] ដូចបានពិភាក្សាក្នុងផ្នែកចុងក្រោយ ស្តង់ដារដឹកនាំគណៈមេធាវីក្នុងស្រុក ក្នុងយុត្តាធិការនានាដែលជួបប្រទះវិបត្តិសង្គម ឬនយោបាយ គឺកំពុងតែខ្វះភាពច្បាស់លាស់ ហើយយកទៅអនុវត្តឲ្យបានទាំងអស់គ្នា។

---

[54] *សូមមើល,* គណៈមេធាវីកាណាដា, គណៈកម្មការនីតិបញ្ញត្តិ និងកំណែទម្រង់ច្បាប់, 'អំពី', មាននៅលើវិបសាយថ៍ http://www.cba.org/Sections/Legislation-and-Law-Reform.

[55] Johnstone, *supra* n.1 at p.228.

[56] *Ibid.*

[57] *សូមមើល, Keller v. រដ្ឋកាលីហ្វ័រញ៉ា,* 496 U.S. 1, No 88-1905 (1990).

[58] ការបង្ហាញរបស់មេធាវីដែលពាក់ព័ន្ធ ជាអ្នកដើរតួនាទីខាងសីលធម៌ ជាជាងអ្នកផ្តល់សេវាកម្ម ត្រូវបានគេចងក្រងក្នុងអក្សរសាស្ត្រអំពីបុព្វហេតុមេធាវី។ សូមមើល, ឧទាហរណ៍, Kieran McEvoy និង Rachel Reoubche, 'ប្រមូលផ្តុំវិជ្ជាជីវៈ? មេធាវី នយោបាយ និងមនសិការច្បាប់រួម,' នៅក្នុង J. Morrison, K. McEvoy និង G. Anthony (eds) *ចៅក្រម សិទ្ធិមនុស្ស និងអន្តរកាល* (Oxford, 2007), pp275-314.

# III. តួនាទីគណៈមេធាវីនៅពេលមានវិវាទ និងវិបត្តិ

លក្ខណៈ និងការទទួលខុសត្រូវនានារបស់គណៈមេធាវី ដែលមានប្រសិទ្ធភាពក្នុងយុត្តាធិការដែលកំពុងជួបប្រទះវិវាទ ឬវិបត្តិ មិនមែនងាយស្រួលកំណត់បានជានិច្ចនោះទេ។ តាមពិត ទីណាដែលមានការរំលោភបំពានសិទ្ធិមនុស្សច្រើន ហើយជាពិសេសការគំរាមកំហែងខ្លាំងដល់សុវត្ថិភាព និងឯករាជ្យនៃវិជ្ជាជីវៈច្បាប់ គណៈមេធាវីមានកិច្ចការដ៏លំបាកក្នុងការស្វែងរកការឆ្លើយតបឲ្យត្រូវនឹងហេតុការណ៍ នយោបាយ និងសកម្មភាព។ ជាពិសេស តើទំនួលខុសត្រូវពិតប្រាកដរបស់មេធាវីក្នុងបរិយាកាសមានវិបត្តិមានអ្វីខ្លះ? តើវាគ្រប់គ្រាន់ទេ ដែលមេធាវីបន្តធ្វើការងារ និងបន្តធ្វើជាតំណាងអតិថិជនក្នុងតុលាការ ឬតើពួកគេមានការទទួលខុសត្រូវ នៅត្រឹមកម្រិតគោលនយោបាយដើម្បីប្រកាន់យកគោលជំហរសាធារណៈ ឬប្រឆាំងនឹងបញ្ហាដែលប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈ? តើសកម្មភាពទាំងនេះ ត្រូវអនុវត្តដោយរបៀបណាឲ្យមានប្រសិទ្ធភាព?

ស្តង់ដារអន្តរជាតិបច្ចុប្បន្ន មានរៀបចំឯកសារយោងតិចតួចទៅលើតួនាទីរបស់គណៈមេធាវីនៅពេលមានវិបត្តិ។ ជំនួសមកវិញការជ្រៀតជ្រែកតាមការឆ្លើយតបដោយប្រសិទ្ធភាព ត្រូវតែដកស្រង់ពីករណីសិក្សានានា និងស្តង់ដារអន្តរជាតិ ដែលមានស្រាប់នៃការអនុវត្តន៍ល្អបំផុត សម្រាប់អ្នកជំនាញច្បាប់។ គួរឲ្យចាប់អារម្មណ៍ណាស់ គោលការណ៍មូលដ្ឋានរបស់អង្គការសហប្រជាជាតិ មិនមានការលើកលែងសម្រាប់រដ្ឋទាំងឡាយណា ដែលមានវិវាទ មានន័យថាការទទួលខុសត្រូវចំពោះវិជ្ជាជីវៈច្បាប់ស្ថិតនៅដូចគ្នាដដែលនៅក្នុងកំឡុងពេលមានអាសន្ន។ សេចក្តីប្រកាសទីក្រុងហ្សឺណែវរបស់ International Commission of Jurists (ICJ) អំពីការលើកស្ទួយច្បាប់ និងតួនាទីចៅក្រម និងមេធាវីនៅពេលមានវិបត្តិ ថ្លែងថា "តួនាទីរបស់វិជ្ជាជីវៈច្បាប់ នៅតែមានសារៈសំខាន់យ៉ាងធំធេង ក្នុងការការពារសិទ្ធិមនុស្ស និងច្បាប់នៅពេលមានវិបត្តិ រាប់ទាំងស្ថានភាពអាសន្នដែលបានប្រកាស"[59] ហើយថ្លែងបន្តទៀតថា "...គណៈមេធាវី មានទំនួលខុសត្រូវផ្ទៃច្បាប់ និងសីលធម៌ ដើម្បីលើកស្ទួយ និងផ្សព្វផ្សាយពីច្បាប់ និងសិទ្ធិមនុស្ស។"[60] ជាពិសេស ទីណាដែលមេធាវីម្នាក់ៗទទួលរងការគំរាមកំហែង ស្តង់ដារអន្តរជាតិ ច្បាស់ថា គណៈមេធាវី មានតួនាទីមួយក្នុងការមកការពារក្តីរបស់ពួកគេ។ អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិអំពីឯករាជ្យភាពរបស់ចៅក្រម និងមេធាវី បានអះអាងថា អង្គការចាត់តាំងតាមវិជ្ជាជីវៈត្រូវបានគេតម្រូវឲ្យចាត់វិធានការចាំបាច់ ក្នុងករណីមានការចាប់ខ្លួន ឬការឃុំខ្លួនមេធាវី។[61] វាពិតជាយល់ច្បាស់ថា គណៈមេធាវីមានតួនាទីសំខាន់មួយ ក្នុងបណ្តារដ្ឋដែលជួបគ្រាអាសន្ន ថាជាបណ្តុំមេធាវី ហើយជាការសម្តែងមតិយោបល់អំពីវិជ្ជាជីវៈច្បាប់។ ប៉ុន្តែកិច្ចព្រមព្រៀងសកល អំពីសកម្មភាពដែលគណៈមេធាវីគួរប្រកាន់យក មិនត្រូវបានគេបង្កើតនៅឡើយទេ។

---

[59] International Commission of Jurists, អត្ថាធិប្បាយអំពីច្បាប់ ចំពោះការប្រកាសនៅទីក្រុង ហ្សឺណែវ ICJ: លើកស្ទួយច្បាប់ និងតួនាទីរបស់ចៅក្រម និងមេធាវី ក្នុងពេលមានវិបត្តិ' 31 ឧសភា 2011, គោលការណ៍ 1។

[60] *Ibid.* គោលការណ៍ 13.

[61] L. Despouy, របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីឯករាជ្យភាពនៃចៅក្រម និងមេធាវី, UN Doc A/64//181, 28 កក្កដា 2009, para 69.

ក្នុងបរិយាកាសមានវិបត្តិ វិជ្ជាជីវៈច្បាប់សកម្មខ្លាំងក្នុងការប្រកាន់យកគោលជំហរនានាលើបញ្ហានយោបាយដែលមានភាពផុយស្រួយខ្លាំង។ ឧទាហរណ៍នៅប៉ាគីស្ថាន សហគមន៍ផ្នែកច្បាប់មានសម្លេងដ៏រឹងមាំ និងជោគជ័យក្នុងការហ៊ានប្រឈមជាមួយគោលនយោបាយរបស់រដ្ឋាភិបាលក្នុងពេល និងក្រោយពេលមានច្បាប់អាជ្ញាសឹក។[62] គណៈមេធាវី ក៏សកម្មផងដែរ ក្នុងការប្រកាន់គោលជំហរចំពោះបញ្ហានយោបាយ និងជាពិសេសក្នុងការតតាំងនឹងការប្រែឲ្យទៅជាប្រព័ន្ធច្បាប់អ៊ីស្លាម។[63] ក្រៅពីនេះ ក្នុងពេលមានវិវាទនៅ Sierra Leone គណៈមេធាវីជាតិ ជាញឹកញាប់បានប្រកាន់យកគោលការណ៍សិទ្ធិមនុស្ស និងបញ្ហាផលប្រយោជន៍សាធារណៈដែលមានផលប៉ះពាល់ដល់ច្បាប់ ជាពិសេសនៅក្នុងការជំរុញឲ្យរដ្ឋាភិបាលធានាថា ការកាត់ទោស មិនត្រូវបានអនុវត្តដោយមានរបៀបវារៈនយោបាយទាក់ទងនឹងវិវាទ និងបម្រើផលប្រយោជន៍ឲ្យក្រុមបក្សពួកបញ្ចូលសំខាន់ណាមួយឡើយ សម្រាប់បញ្ហាសិទ្ធិមនុស្ស។[64] IBA សកម្មជាពិសេសនៅក្នុងការគំរាមកំហែងថ្កោលទោសជាសាធារណៈចំពោះវិជ្ជាជីវៈច្បាប់ វិធាននៃច្បាប់ ឬចំពោះសិទ្ធិមនុស្ស។ ឧទាហរណ៍ IBA បានបញ្ចេញមតិយោបល់ប្រឆាំងនឹងការគំរាមកំហែងនានា ចំពោះឯករាជ្យភាពនៃវិជ្ជាជីវៈច្បាប់នៅស្រីឡង្កា មេធាវីដែលបានចាប់ខ្លួននៅទួគី និងការគំរាមកំហែងផ្សេងទៀតប្រឆាំងនឹងមេធាវីនៅប្រទេសហ្ស៊ីមបាវេ។[65]

ក្រៅពីនេះ ទីណាដែលមិនមានសកម្មភាពដ៏ប្រសិទ្ធភាពមកលើផ្នែកមួយនៃគណៈមេធាវី ក្នុងពេលមានវិបត្តិ នោះការរិះគន់យ៉ាងច្រើន បានកើតមានតាមក្រោយ។ ឧទាហរណ៍នៅពេលមានវិវាទនៅ អៀរឡង់ខាងជើង វិជ្ជាជីវៈច្បាប់ បរាជ័យយ៉ាងដំណំក្នុងការឆ្លើយតបនឹងហេតុការណ៍នយោបាយខ្លួនឯង។ [66] បើទោះជាមានការថ្កោល

---

[62] R. Mehdi, *The Islamization of the law in Pakistan*, (Curzon Press: 1994), para 1.8.1.

[63] *Ibid.*

[64] M. O'Flaherty, 'ដំណើរសន្តិភាពរបស់ប្រទេស Sierra Leone' នៅក្នុង E. Lutz និង E. Babbitt (eds), *សិទ្ធិមនុស្ស និង ដំណោះស្រាយវិវាទក្នុងបរិបទ៖ កូឡុំបៀ សេរ៉ាឡេអូន និងអៀរឡង់ខាងជើង។* (Syracuse, 2009), p.95; សូមមើលផងដែរ, Niobe Thompson, 'ការប្តឹងស្វែងរកយុត្តិធម៌៖ របាយការណ៍មួយអំពីតុលាការនៅប្រទេស សេរ៉ាឡេអូន' របាយការណ៍របស់គំនិតផ្តួចផ្តើមសិទ្ធិមនុស្ស Commonwealth និងគណៈមេធាវីសេរ៉ាឡេអូន, 2002, p.35. មាននៅលើវ៉ិបសាយថ៍ http://www.humanrightsinitiative.org/publications/ffm/sierra_leone_report.pdf

[65] *សូមមើល,* IBA, 'IBA បង្ហាញក្តីកង្វល់ចំពោះកាត់ទោសមេធាវីបួនរូប, ទួរគី, មករា 2004', 20 មករា 2004, Available at http://www.ibanet.org/Human_Rights_Institute/About_the_HRI/HRI_Activities/HRI_Media/HRI_Interventions/archive/200104_Turkey.aspx; IBA, 'Sri Lanka: IBAHRI ធ្វើការណែនាំឲ្យមានការការពារប្រព័ន្ធយុត្តិធម៌ វិជ្ជាជីវៈច្បាប់ និងប្រព័ន្ធផ្សព្វផ្សាយនៅ peril,' 26 ឧសភា 2009, មាននៅលើ វ៉ិបសាយថ៍ http://www.ibanet.org/Article/Detail.aspx?ArticleUid=7DF2962F-7769-4FAF-8E16-6371B408C174; IBA, 'IBAHRI បានថ្កោលទោសអំពើហិង្សា និងការគំរាមកំហែងថ្មីនេះ ដែលធ្វើឡើងប្រឆាំងនឹងមេធាវីហ្ស៊ីមបាវេ ដោយប៉ូលីស និងមន្ត្រីដទៃទៀត,' 22 មីនា 2007, មាននៅលើវ៉ិបសាយថ៍ http://www.ibanet.org/Article/Detail.aspx?ArticleUid=2402BBB3-3819-4511-BA6E-88FE10CAB1F1.

[66] McEvoy, *supra* n.4 at p.369.

ទោសជាផ្លូវការអំពីការសម្លាប់ទ្រង់ទ្រាយធំក៏ដោយ ក៏សង្គមអ្នកច្បាប់ បានសម្រេចចិត្តមិនអំពាវនាវឲ្យមានការស៊ើបអង្កេតជាផ្លូវការ ឬចូលពាក់ព័ន្ធនៅកម្រិតខ្ពស់ជាងនេះ ជំនួសឲ្យការអះអាងថា គោលនយោបាយរបស់សង្គមអ្នកច្បាប់នៃ "អព្យាក្រិត្យភាព" ហាមមិនឲ្យចូលពាក់ព័ន្ធក្នុងសកម្មភាពដែលគេឃើញថាជារឿងនយោបាយទាំងស្រុងទៅវិញ។[67] ខណៈដែលមេធាវីជាច្រើន បានបន្តការងាររបស់ពួកគេ McEvoy កត់សម្គាល់ថា អ្នកដែលបានបញ្ចេញមតិយោបល់ប្រឆាំងនឹងការរំលោភសិទ្ធិមនុស្ស និងការគំរាមកំហែងដល់ច្បាប់ ត្រូវបានគេចោទប្រកាន់ពីបទធ្វើឲ្យប៉ះពាល់ដល់អព្យាក្រិត្យភាពនៃវិជ្ជាជីវៈ។[68] លើសពីនេះ សង្គមអ្នកច្បាប់នៃអៀរឡង់ខាងជើងមិនបានធ្វើការបញ្ជូនឲ្យមានការស៊ើបអង្កេតណាមួយ ដែលបានរាយការណ៍លើប្រព័ន្ធច្បាប់អាសន្ន។[69] អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ អំពីឯករាជ្យភាពរបស់មេធាវី និងចៅក្រម បានសន្និដ្ឋានថា ការគ្មានសកម្មភាពនៃសង្គមអ្នកច្បាប់ បានរំលោភលើភារៈកិច្ចនៃក្រមវិជ្ជាជីវៈ ក្រោមគោលការណ៍មូលដ្ឋានរបស់អង្គការសហប្រជាជាតិ ដែលប្រគល់កាតព្វកិច្ចទៅឲ្យគណៈមេធាវី ដើម្បីធានាថាមេធាវី អាចអនុវត្តភារៈកិច្ចរបស់ពួកគេដោយគ្មានការជ្រៀតជ្រែកដែលមិនសមរម្យ។[70]

វិជ្ជាជីវៈច្បាប់នៅអាហ្រ្វិកខាងត្បូង ក៏ត្រូវបានគេរិះគន់ចំពោះភាពស្ងៀមស្ងាត់របស់ខ្លួន ក្នុងរបបរើសអើងពណ៌សម្បុរ។ គណៈកម្មាធិការស្វែងរកការពិត និងសម្រុះសម្រួល បានរកឃើញថាក្រុមប្រឹក្សាមេធាវីមានការ "ពាក់ព័ន្ធនឹងសកម្មភាពខុសច្បាប់" តាមរយៈភាពស្ងៀមស្ងាត់របស់ខ្លួនចំពោះគោលនយោបាយរើសអើងពណ៌សម្បុរ ហើយមិន "មានគំនិតផ្តួចផ្តើមដែលមានប្រសិទ្ធភាពណាមួយ ដើម្បីធ្វើឲ្យការគ្រប់គ្រងយុត្តិធម៌ អាចទទួលយកបាន" ហើយដកហូតមេធាវីណា ដែលជាសកម្មជនប្រឆាំងនឹងការរើសអើងពណ៌សម្បុរនេះ។[71] វិជ្ជាជីវៈច្បាប់ ត្រូវបានគេមើលឃើញថាមាននយោបាយអនុប្បវាទ និងគេចពីបញ្ហាយុត្តិធម៌ ដែលទាក់ទងនឹងប្រព័ន្ធរើសអើង ហើយបដិសេធមិនប្រើប្រាស់ទេពកោសល្យវិជ្ជាជីវៈរបស់ពួកគេ ដើម្បីតវ៉ាប្រឆាំងនឹងការរើសអើងនេះ។[72] ក្រៅពីនេះ នៅមានវប្បធម៌ដ៏រឹងមាំមួយទៀត ក្នុងការរារាំងវិជ្ជាជីវៈ ចំពោះការចូលរបស់អាហ្រ្វិកស្បែកខ្មៅទៅក្នុងវិជ្ជាជីវៈច្បាប់។[73] គណៈមេធាវីជាច្រើនពីយុត្តាធិការផ្សេងទៀត ដែលជួបប្រទះវិវាទ រាប់បញ្ចូលទាំងប្រទេស កម្ពុជា

---

[67] Ibid. p.370-1.

[68] Ibid. p.383.

[69] Ibid. p.365.

[70] P. Cumaraswamy, 'របាយការណ៍អំពីបេសកកម្មនៃអ្នករាយការណ៍ពិសេសប្រចាំនៅចក្រភពអង់គ្លេស និងអៀរឡង់ខាងជើង', UN Doc E/CN.4/1999/39/Add.4, 5 មីនា 1998។

[71] 'គណៈកម្មាធិការស្វែងរកការពិត និងសម្រុះសម្រួល, របាយការណ៍ចុងក្រោយ', វ៉ុលទី 4, ជំពូកទី 4, Subsection 3, paras 29-34.

[72] John Dugard, 'សិទ្ធិមនុស្ស, ការរើសអើងពណ៌សម្បុរ និងមេធាវី។ តើមានមេរៀនពីមេធាវីណា ដែលមកពីប្រទេស ដែលប្រើច្បាប់ទូទៅឬទេ?' *University of New South Wales Law Journal,* 15(2), 1991, pp. 444-445.

[73] *Ibid.*

អ៊ីស្រាអែល រដ្ឋអាមេរិកឡាទីន ក៏បានទទួលការរិះគន់ចំពោះការមិនប្រកាន់ជំហររឹងមាំល្មមប្រឆាំងនឹងការគំរាមកំហែងមកលើច្បាប់ ឬសិទ្ធិមនុស្ស។[74]

រចនាសម្ព័ន្ធ និងការរៀបចំនៃគណៈមេធាវី អាចបណ្តាលឲ្យមានឧបសគ្គចំពោះការចូលរួមរបស់ពួកគេ ក្នុងពេលមានវិបត្តិ ហើយអាចបង្អាក់សមត្ថភាពរបស់ពួកគេ ក្នុងការប្រកាន់គោលជំហរប្រកបដោយប្រសិទ្ធភាពប្រឆាំងនឹងការគំរាមកំហែងទាំងឡាយចំពោះផលប្រយោជន៍សាធារណៈ។ នៅក្នុងយុត្តាធិការខ្លះ ដែលភាពស្មោះត្រង់ចំពោះរដ្ឋបានកប់ជ្រៅក្នុងវប្បធម៌ច្បាប់ក្នុងស្រុក គណៈមេធាវីអាចស្ទាក់ស្ទើរក្នុងការធ្វើការរិះគន់។[75] ការណ៍នេះអាចពាក់ព័ន្ធជាពិសេសក្នុងវប្បធម៌ច្បាប់ ដូចជា អៀរឡង់ខាងជើង ដែល "អព្យាក្រិត្យភាព" គឺជាគោល ការណ៍ដ៏សំខាន់មួយ។ ក្នុងយុត្តាធិការដទៃ កិច្ចព្រមព្រៀងជាសកលលើគោលជំហរមួយ ជាពិសេសនៅពេល គណៈមេធាវីមួយ មានភាពទីទៃពីគ្នាខាងទស្សនៈនយោបាយ ដែលមិនអាចសម្រុះសម្រួលបាននៅក្នុងក្រុមសមាជិករបស់ខ្លួន បានបញ្ជាក់ថាបណ្តាលឲ្យមានអសមត្ថភាព និងអសកម្មភាព លើផ្នែកមួយនៃគណៈមេធាវី បើទោះជាស្ថិតក្នុងស្ថានភាពមានវិបត្តិក៏ដោយ។[76] ជាការពិត ជាជាងការនាំទៅរកសកម្មភាពមួយដែលប្រាកដ នៅលើផ្នែកមួយនៃគណៈមេធាវី ដូចជាភាពផ្សេងគ្នាទស្សនៈ ទំនោរទៅរកការជាប់គាំង ឬមានសកម្មភាពតិចតួច។[77] គណៈមេធាវី អាចអនុម័តគោលនយោបាយអព្យាក្រិត្យ ដែលពួកគេយល់ឃើញថា ពួកគេត្រូវតែជាតំណាងឲ្យសមាជិកទាំងអស់ ហើយត្រូវតែខិតខំបំពេញតាមបំណងសមាជិកក្រុមផ្សេងៗគ្នា។[78]

ជាញឹកញាប់ បញ្ហាប្រឈមចំពោះអង្គភាព និងរចនាសម្ព័ន្ធ និងគោលនយោបាយអព្យាក្រិត្យទាំងនេះ បង្កើតបានជាភាពតានតឹងមួយរវាងគណៈមេធាវី និងមេធាវីម្នាក់ៗ ដែលបម្រើបុព្វហេតុក្នុងពេលមានវិបត្តិ ឬវិវាទនយោបាយ។ មេធាវីដែលបម្រើបុព្វហេតុខ្លះ បំពេញការងារដើម្បីបុព្វហេតុច្រើន ឬប្រើប្រាស់ល្បិចដែលមិននិយមក្នុងផ្នែកនយោបាយ ដែលបណ្តាលឲ្យមានបញ្ហាសម្រាប់គណៈមេធាវី ដែលពួកគេជាសមាជិក។ ប៉ុន្តែមានឧទាហរណ៍ជាច្រើន មេធាវីដែលបម្រើបុព្វហេតុ អាចជំរុញឲ្យគណៈមេធាវីនានាប្រកាន់យកគោលជំហរផ្សេងៗអំពីបញ្ហានយោបាយសំខាន់ៗ បើទោះជាពេលមិនពេញនិយមក៏ដោយ ឬនៅពេលពួកគេ សម្របសម្រួលឲ្យមានអព្យាក្រិត្យភាពខាងនយោបាយរបស់គណៈមេធាវីមួយ។ ឧទាហរណ៍ Sarat និង Scheingold លើកឡើងថាការបម្រើបុព្វហេតុជាមេធាវី នៅសហរដ្ឋអាមេរិក ចុងបញ្ចប់បានជំរុញឲ្យគណៈ មេធាវីអាមេរិកាំង ធ្វើសេចក្តីថ្លែងការទាមទារឲ្យមានការបញ្ឈប់ភ្លាមលើបញ្ហាការផ្តន្ទាទោសអស់មួយជីវិត។[79] ស្រដៀងគ្នាដែរ McEvoy និង

---

[74] McEvoy, *supra* n.4 at p.353.

[75] *Ibid.* p.380.

[76] Chambliss and Green, *supra* n.31.

[77] *Ibid.*

[78] *Ibid.*

[79] *សូមមើល,* A. Sarat និង S. Scheingold, *អ្វីមួយដែលត្រូវជឿលើ៖ នយោបាយ វិជ្ជាជីវៈ និងបុព្វហេតុមេធាវី,* (Stanford: OUP) 2004. *សូមមើលផងដែរ* K.McEvoy និង R. Rebouche 'ការប្រមូលផ្តុំវិជ្ជាជីវៈ មេធាវី នយោបាយ និងមនសិការច្បាប់រួម'។ នៅក្នុង J. Morrison, K McEvoy និង G. Anthony (eds) *ចៅក្រម សិទ្ធិមនុស្ស និងអន្តរកាល* (Oxford: OUP, 2007) pp.275-314.

Rebouche លើកឡើងថា ការតស៊ូរវាងសកម្មជន និងគណៈមេធាវីក្នុងបរិយាកាសមានវិបត្តិ នៅទីបំផុតនាំឲ្យមេធាវីដែលជាសកម្មជន ញុះញង់ឲ្យមានមនសិកាច្បាប់របស់គណៈ មេធាវីនៅតាមទីកន្លែង ដូចជាអៀរឡង់ខាងជើង និងអាហ្វ្រិកខាងត្បូង បើទោះជាមានកាលៈទេសៈនយោ បាយផ្លាស់ប្តូរក៏ដោយ។[80]

បើទោះជាមានបញ្ហាទាំងនេះ វាហាក់ដូចជាមានស្តង់ដារអន្តរជាតិមួយដែលកំពុងងើបឡើងសម្រាប់សមាគមវិជ្ជាជីវៈមេធាវី ចូលរួមក្នុងការឆ្លើយតបនឹងវិបត្តិ ហើយប្រកាន់យកគោលជំហរពិបាក និងជាញឹកញាប់មានភាពចំរូងចំរាស់ ដើម្បីការពារច្បាប់ និងសិទ្ធិមនុស្ស។ គោលនយោបាយផ្លូវការនៃ "អព្យាក្រិត្យភាព" របស់គណៈ មេធាវី ឬវប្បធម៌ច្បាប់ដែលសង្កត់ធ្ងន់លើភាពស្មោះត្រង់ចំពោះរដ្ឋ ត្រូវបានគេរិះគន់ពីការមិនបញ្ចេញមតិយោបល់គ្រប់គ្រាន់ប្រឆាំងនឹងការគំរាមកំហែងចំពោះវិធាននៃច្បាប់ និងសិទ្ធិមនុស្ស។ បើទោះជាគណៈមេធាវី អាចសម្តែងចំណង់របស់ខ្លួនក្នុងការស្ថិតនៅអព្យាក្រិត្យក៏ដោយ ក៏ជ្រុងរវាងច្បាប់និងនយោបាយ គឺជាតថភាពមួយយ៉ាងសំខាន់ដែលពាក់ព័ន្ធនឹងវិជ្ជាជីវៈច្បាប់ក្នុងបញ្ហានយោបាយ តាមរយៈភាពស្ងៀមស្ងាត់របស់ពួកគេ ឬការគាំទ្ររបស់ពួកគេ។ ទន្ទឹមនឹងនេះ ការដាក់បញ្ចូលសិទ្ធិមនុស្សទៅក្នុងក្រមប្រតិបត្តិ និងការសង្កត់ធ្ងន់ជាថ្មីអំពីច្បាប់ មាននិន្នាការសំខាន់មួយក្នុងចំណោមគណៈមេធាវីទាំងនោះ។ គណៈមេធាវីទាំងឡាយដែលប្រកាន់យកគោលជំហររួម ជារឿយៗអាចការពារឯករាជ្យភាពវិជ្ជាជីវៈច្បាប់ ដោយយកចេញការគំរាមកំហែង ប្រឆាំងនឹងសមាជិកម្នាក់ៗ។ តាមពិតគោលជំហររួមពីគណៈមេធាវី នឹងកាត់បន្ថយហានិភ័យដល់មេធាវីម្នាក់ៗ ដែលប្រកាន់យកគោលជំហរមួយ ដែលអាចធ្វើឲ្យពួកគេប្រឈមនឹងការគំរាមកំហែង ការរិះគន់ ឬការបាត់បង់អតិថិជន។[81] ការណ៍នេះមានសារៈសំខាន់ ជាពិសេសក្នុងករណីដូចជា អៀរឡង់ខាងជើង ដែលមេធាវីទទួលរងការគំរាមកំហែងជាទៀងទាត់ សម្រាប់ការទៅតំណាងអតិថិជនមួយចំនួន ឬសម្រាប់ទស្សនៈនយោបាយរបស់ពួកគេ ដែលផ្ទុយនឹងភាពស្ងៀមស្ងាត់របស់សង្គមអ្នកច្បាប់លើបញ្ហានានា។ នៅក្នុងឧទាហរណ៍មួយចំនួនដែលបានលើកឡើង វាគឺជាការរិះគន់យ៉ាងច្បាស់អំពីភាពស្ងៀមស្ងាត់នៃវិជ្ជាជីវៈច្បាប់ នៅពេលមានវិបត្តិដែលដើរតួជា 'ពេលវេលាដ៏សំខាន់' ក្នុងវប្បធម៌ច្បាប់នីមួយៗ ដោយផ្តល់នូវការលើកទឹកចិត្តសម្រាប់គណៈមេធាវីឲ្យកាន់តែមានសំឡេងក្នុងការប្រកាន់យកគោលជំហរនានា លើបញ្ហាសង្គម និងនយោបាយ។[82] ដូចបាន កត់ចំណាំខាងលើ ទាំងអៀរឡង់ខាងជើង ទាំងអាហ្វ្រិកខាងត្បូង ជាលទ្ធផលនៃការបញ្ចុះបញ្ចូលខាងក្នុង និងសម្ពាធពីមេធាវី នៅទីបំផុតបានអនុម័តយកគោលជំហរវឌ្ឍនភាពខ្លាំងជាងមុន ក្នុងបញ្ហានយោបាយទំនើប នៅតាមយុត្តាធិការរបស់ពួកគេ

[80] *Ibid.*

[81] K. Mills, *ការការពារសិទ្ធិមនុស្សក្នុងនយោបាយសកលៈ ការទទួលខុសត្រូវនៃរដ្ឋ និងតួអង្គមិនមែនជា រដ្ឋ* (Palgrave: 2015), p.196.

[82] Kieran McEvoy និង Rachel Rebouche, 'ការប្រមូលផ្តុំវិជ្ជាជីវៈ? មេធាវី នយោបាយ និងមនសិការច្បាប់រួម' នៅក្នុង J. Morrison, K. McEvoy និង G. Anthony (eds) *ចៅក្រម សិទ្ធិមនុស្ស និងអន្តរកាល* (Oxford: OUP, 2007), pp. 275-314.

រៀងៗខ្លួន។[83] តាមពិតរដ្ឋធម្មនុញ្ញរបស់គណៈមេធាវីអាហ្វ្រិកខាងត្បូង ឥឡូវនេះបញ្ចូលជាកម្មវត្ថុស្នូលរបស់ខ្លួន គឺការទទួលខុសត្រូវក្នុងការដើរតួជា "ភ្នាក់ងារផ្លាស់ប្តូរនៅអាហ្រិកខាងជើងក្រោយមានការរើសអើងពណ៌សម្បុរ និងខិតខំឆ្ពោះទៅរកឧត្តមគតិនៃការមិនរើសអើងពូជសាសន៍ និងភេទ ក្នុងសង្គមដែលបើកចំហ។"[84] គោលជំហរបែបនេះ គឺជាការវិវឌ្ឍន៍ដ៏សំខាន់ពីការនៅស្ងៀមស្ងាត់តាមចរិកលក្ខណៈ និងអព្យាក្រិត្យភាពនៃគណៈមេធាវីនៅក្នុងសម័យកាលមានការរើសអើង។

ប៉ុន្តែនៅមានតម្រូវការយ៉ាងច្បាស់មួយសម្រាប់ការអភិវឌ្ឍន៍ស្តង់ដារស្តីពីតួនាទីដែលគណៈមេធាវីមាននៅកន្លែងដែលមានអាសន្ន។ វាក៏មិនយល់ច្បាស់គ្រប់គ្រាន់ ថាតើពេលណាគណៈមេធាវី គួរអន្តរាគន៍លើបញ្ហានានាដែលនៅក្រៅវិជ្ជាជីវៈច្បាប់។ ប្រព័ន្ធច្បាប់អាមេរិក បានរកឃើញថា គណៈមេធាវីអាចប្រកាន់យក គោលជំហរួមមួយនៅពេលបញ្ហានោះវា "ពាក់ព័ន្ធ" នឹងគោលបំណងរបស់គណៈមេធាវី។[85] ខណៈដែលមានស្តង់ដារមួយសម្រាប់ការវាស់ស្ទង់ការចូលរួមរបស់គណៈមេធាវីនៅក្នុងដំណើរការនយោបាយ ដែលមានការគំរាមកំហែងដល់សិទ្ធិមនុស្ស ច្បាប់ ឬឯករាជ្យភាពនៃវិជ្ជាជីវៈច្បាប់ ការអនុវត្តន៍ល្អបំផុត សម្រាប់ថ្នាក់អន្តរជាតិ នឹងត្រូវដាក់ពង្រាយ ហើយជាញឹកញាប់បានកំណត់ត្រឹមរបាយការណ៍សាធារណៈ។ ស្តង់ដារអន្តរជាតិដែលមានលក្ខណៈច្បាស់លាស់ជាងនេះ ត្រូវតែបង្កើតឡើងដើម្បីកំណត់ការទទួលខុសត្រូវ របស់អង្គការចាត់តាំងរបស់មេធាវីនៅពេលមានវិបត្តិ។ ដើម្បីធ្វើដូច្នោះ គណៈមេធាវីមានកិច្ចការដ៏ពិបាកក្នុងការកំណត់អាទិភាពលើកម្មវត្ថុ និងអាណត្តិ និងការថ្លឹងថ្លែងរវាងកម្មវត្ថុដែលមានវិវាទខ្លាំង។ ឧទាហរណ៍កន្លែងណាដែលមានទស្សនៈនយោបាយក្នុងគណៈមេធាវីមួយ ការពារមិនឲ្យមានជំហររួមលើបញ្ហាមួយ ថ្នាក់ដឹកនាំរបស់គណៈមេធាវី ត្រូវតែសម្រេចចិត្តថាតើការមិនយល់ព្រមនោះ ទប់ស្កាត់មិនឲ្យមានសកម្មភាពរួម តាមតម្រូវការចាំបាច់។ ឬទីណាដែលសង្គមអ្នកច្បាប់មានគោលការណ៍ផ្លូវការអំពីអព្យាក្រិត្យភាព និងឯករាជ្យ ប៉ុន្តែដំណើរការក្រោមយុត្តាធិការដែលច្បាប់ និងសិទ្ធិមនុស្សទទួលរងនូវការគំរាមកំហែងយ៉ាងខ្លាំង គណៈមេធាវីត្រូវតែថ្លឹងថ្លែងរវាងគោលការណ៍អព្យាក្រិត្យរបស់ខ្លួន និងតួនាទីរបស់វាក្នុងការការពារមេធាវី ដើម្បីអំពាវនាវឲ្យមានការសួរនាំ និងថ្កោលទោសការរំលោភបំពានដែលរាលដាល។

[83] *Ibid.*

[84] អគ្គក្រុមប្រឹក្សាមេធាវីអាហ្វ្រិកខាងត្បូង, ធម្មនុញ្ញដែលមានវិសោធនកម្ម ដែលឯកភាពរហូតមកដល់ ខែកក្កដា 2012 ដែលមានក្នុងមាត្រា 2(d), មាននៅលើវិបសាយថ៍ http://www.sabar.co.za/about.html

[85] *សូមមើល, Keller v. រដ្ឋកាលីហ្វ័រញ៉ា,* 496 U.S. 1, No 88-1905 (1990).

ការលំបាកផ្សេងទៀត ក៏នៅតែមាននៅពេលមានវិបត្តិ និងវិវាទ ដែលធ្វើឲ្យមានបញ្ហាប្រឈមចំពោះប្រសិទ្ធភាពនៃគណៈមេធាវី។ ជាពិសេសបញ្ហាប្រឈម គឺជាបញ្ហាអំពើពុករលួយកក្នុងសង្គមដែលរាលដាលនៅក្នុងយុត្តាធិការជាច្រើន ដែលជួបប្រទះវិវាទ។ បើទោះជាមានស្តង់ដារអន្តរជាតិទូទៅ ដែលដឹកនាំតួនាទី និងសកម្មភាពរបស់គណៈមេធាវីសកម្មទាំងនេះ មានការលំបាកអនុវត្តនៅកន្លែងណាដែលមានអំពើពុករលួយនៅក្នុងគណៈមេធាវី វិជ្ជាជីវៈច្បាប់ ឬការិយាធិបតេយ្យរដ្ឋ។ ការអនុវត្តន៍សកម្មភាពសំខាន់ៗសម្រាប់គណៈមេធាវី គឺមានការស្មុគស្មាញនៅកន្លែងណាដែលអំពើពុករលួយ មានការរាលដាលក្នុងសង្គមកាន់តែធំឡើង ដោយសារភាពឯករាជ្យនៃវិជ្ជាជីវៈច្បាប់ ជាញឹកញាប់ត្រូវបានគេសម្របសម្រួល ហើយគណៈមេធាវី គឺចូលលាយឡំផ្នែកអតិថិជននិយមខាងនយោបាយ។ នៅក្នុងយុត្តាធិការមួយចំនួន គណៈមេធាវីត្រូវបានគេ រិះគន់ថាស្តាប់បង្គាប់សាខាប្រតិបត្តិ។ គណៈមេធាវី និងវិជ្ជាជីវៈច្បាប់ ជាទូទៅមានការសម្រេចចិត្តពិបាក ថាតើត្រូវចូលរួមក្នុងអ្វីដែលគេមើលឃើញថាជាទូទៅថាជា "ប្រព័ន្ធដែលប្រើមធ្យោបាយទុច្ចរិត"។ ដោយគោរពតាមបញ្ហាសឹកអាមេរិក ដើម្បីប្រើប្រាស់ស្នងការយោធានៅឈូងសមុទ្រ Guantanamo កាត់ទោសភេរវករដែលចាប់បាន ឬអ្នកសហការ មានការរិះគន់ខ្លាំងឡើងអំពីនីតិវិធីរបស់ស្នងការ។[86] យោងតាម Cheh បានឲ្យដឹងថា គណៈមេធាវីអាមេរិកផ្សេងៗ បានរិះគន់នីតិវិធី និងការណែនាំ ប៉ុន្តែមិនបានចូលពាក់ព័ន្ធ ថាតើមេធាវីស៊ីវិល គួរចូលរួមក្នុងនីតិវិធីតុលាការឬអត់។[87] ប៉ុន្តែគណៈមេធាវីជាតិការពាររឿងក្តីព្រហ្មទណ្ឌ ថែងថា លក្ខខណ្ឌដែលបានដាក់ក្នុងការព្រមាន មិនអាចដំណើរការទៅរួចក្នុងការផ្តល់បទបង្ហាញគ្រប់គ្រាន់ និងមានសីលធម៌ ហើយណែនាំឲ្យសមាជិករបស់ខ្លួន មិនឲ្យចូលរួមឡើយ។[88]

រចនាសម្ព័ន្ធគណៈមេធាវី បេសកកម្ម និងកម្មវត្ថុនានា តួនាទីរបស់ខ្លួនក្នុងការធានាទទួលបាន សេវាផ្នែកច្បាប់ និងបទបញ្ញត្តិ និងការបណ្តុះបណ្តាល អាចត្រូវបានគេសម្របសម្រួលទាំងអស់ ដោយបញ្ហាពុករលួយ ការជ្រៀតជ្រែកពីថ្នាក់ប្រតិបត្តិ ឬកត្តាដទៃទៀត ដែលបានពិភាក្សាខាងលើ។ ដោយមានបញ្ហាប្រឈមទាំងអស់ខាងលើសម្រាប់គណៈមេធាវីនៅពេលស្ថិតក្នុងស្ថានភាពមានវិបត្តិ និងវិវាទ អាចមានតម្រូវការមួយក្នុងការដោះស្រាយបញ្ហាសង្គម និងរចនាសម្ព័ន្ធដែលកាន់តែរីកធំឡើង ដើម្បីអាចអនុវត្តសកម្មភាពខាងក្នុង កែលម្អប្រសិទ្ធភាពរបស់គណៈមេធាវី។ គណៈមេធាវី អាចមានតួនាទីក្នុងការបញ្ចុះបញ្ចូលអាជ្ញាធររដ្ឋ ដើម្បីកែប្រែឧបសគ្គខាងរចនាសម្ព័ន្ធ និងនីតិវិធី ដើម្បីធានាថា ពួកគេអាចអនុវត្តតួនាទីដែលបានពិពណ៌នា ខាងលើ។ គណៈមេធាវីដទៃទៀត ប្រឈមនឹងការងារលំបាកក្នុងការសម្រេចចិត្ត ថាតើត្រូវចូលរួមឬអត់ ក្នុងបរិបថ ដែលឧបសគ្គខាងរចនាសម្ព័ន្ធ និងសង្គម គឺជាឧបសគ្គមួយ ដែលការប្តឹងរកយុត្តិធម៌ មិនអាចធ្វើទៅបាន។

---

[86] M. Cheh, 'តើមេធាវីគួរចូលរួមក្នុងប្រព័ន្ធដែលមាន៖ ករណីស្នងការសឹក' I. J. Nat'l Security & Pol'y 375 (2005), pp 20-21.

[87] *Ibid.*

[88] *Ibid.*

## សន្និដ្ឋាន – តើមានស្តង់ដារសម្រាប់គណៈមេធាវីដែលមានប្រសិទ្ធភាពឬទេ?

ដំណើរការដោយប្រសិទ្ធភាពរបស់គណៈមេធាវី បានក្លាយទៅជាចំណុចសំខាន់ចំពោះការរៀបចំ បទបញ្ញត្តិ និងឯករាជ្យភាពនៃវិជ្ជាជីវៈច្បាប់។ មានកម្មវត្ថុដែលបានលើកឡើងយ៉ាងច្បាស់ចំពោះការអនុវត្តន៍ល្អ នៅក្នុងបណ្តាគណៈមេធាវីគ្រប់យុត្តាធិការទាំងអស់។ ប៉ុន្តែការប្រៀបធៀបក្នុងចំណោមគណៈមេធាវីទាំងនោះ នៅថ្នាក់តំបន់ និងថ្នាក់ជាតិ លាតត្រដាងឲ្យឃើញទាំងចំណុចរួម និងខុសគ្នាខាងអាណត្តិ ការរៀបចំ និងការរៀបចំកម្មវិធី។ ការអនុវត្តល្អបំផុត គឺត្រូវបានគេវាយតម្លៃជាទូទៅក្នុងយុត្តាធិការប្រជាធិបតេយ្យ ដោយយោងទៅលើស្តង់ដារនៃការរៀបចំ និងរចនាសម្ព័ន្ធ ភាពទីទៃពីគ្នា និងការដាក់បញ្ចូលគ្នា បទបញ្ញត្តិ និងការបណ្តុះបណ្តាល និងការការពារឯករាជ្យភាពនៃវិជ្ជាជីវៈច្បាប់។ ស្តង់ដារទាំងនេះ ប្រើជាគោលការណ៍ ណែនាំអន្តរជាតិសម្រាប់គណៈមេធាវីដទៃទៀត។ ក្រៅពីនេះ ស្តង់ដារអន្តរជាតិ បានលេចឡើងសម្រាប់ការអភិវឌ្ឍន៍គណៈមេធាវីដ៏មានប្រសិទ្ធភាព ដែលអនុញ្ញាតឲ្យមានកម្រិតត្រូវគ្នាមួយនៅតាមបណ្តាយុត្តាធិការ ស្របពេលនេះដែរ ក៏អនុញ្ញាតឲ្យមានភាពខុសគ្នានៅក្នុងវប្បធម៌ច្បាប់ក្នុងតំបន់ផងដែរ។ ប៉ុន្តែនៅតែមានចន្លោះដ៏សំខាន់មួយ ក្នុងស្តង់ដារនានាសម្រាប់គណៈមេធាវី ដែលមានមុខងារក្នុងបរិយាកាសដែលមានវិបត្តិ ឬវិវាទ។ ការអនុវត្តន៍ជាអន្តរជាតិ ណែនាំយ៉ាងច្បាស់ពីការទទួលខុសត្រូវយ៉ាងច្បាស់ក្នុងការចូលរួមក្នុងកម្រិតខ្លះ ដើម្បីការពារច្បាប់ និងឯករាជ្យភាពនៃវិជ្ជាជីវៈច្បាប់។ ការពិតកន្លែងណាដែលគណៈមេធាវី ខកខានមិនបានចូលរួមទាល់តែសោះ ការរិះគន់ខ្លាំងបានកើតមាន។ ប៉ុន្តែមានទិសដៅច្បាស់ពីរបីចំពោះគណៈមេធាវី អំពីប្រភេទ និងអំណាចនៃការចូលរួមជាមួយបញ្ហានយោបាយ ឬសង្គមក្នុងយុត្តាធិការផ្ទាល់ខ្លួនរបស់ពួកគេ ពេលស្ថិតក្នុងស្ថានភាពមានវិវាទ។ ការស្របមតិជាទូទៅកាន់តែខ្លាំងមកលើស្តង់ដារសម្រាប់ការចូលរួមដែលមានប្រសិទ្ធភាពនៃវិជ្ជាជីវៈច្បាប់ គឺសំខាន់ក្នុងការធានាឲ្យមានការគោរពសិទ្ធិមនុស្សមូលដ្ឋាន។ ស្តង់ដារអន្តរជាតិ អាចមានប្រយោជន៍ក្នុងការបង្កើតតួនាទីសម្រាប់គណៈមេធាវីនៅពេលមានវិបត្តិ និងវិវាទ ដូចជា៖

- គណៈមេធាវីគួរប្រកាន់ជំហរនៅពេលការពារច្បាប់ និងឆ្លើយតបនឹងគណៈកម្មការរំលោភសិទ្ធិមនុស្សនៅពេលណា និងដោយរបៀបណា
- ការធានាទទួលបានសេវាកម្មច្បាប់តាមរយៈសេវាកម្មច្បាប់ទទួលរ៉ាប់រងឥតមិនគិតថ្លៃឈ្នួល ជាពិសេសអតិថិជនមានប្រាក់ចំណូលទាប ជាពិសេសនៅកន្លែងណាដែលវិបត្តិ ឬវិវាទ មានផលប៉ះពាល់ដល់សហគមន៍ភាគតិច ហើយសម្របសម្រួលសមត្ថភាពរបស់ពួកគេ ដើម្បីទទួលបានសេវាកម្មបែបនោះ។
- របៀបការពារឯករាជ្យភាពនៃវិជ្ជាជីវៈច្បាប់ពីការជ្រៀតជ្រែកពីរដ្ឋ នៅពេលមានវិបត្តិ។
- យន្តការការពារមេធាវី និងស្វែងរកយុត្តិធម៌សម្រាប់មេធាវី ដែលជីវិតរបស់ពួកគេ ទទួលបានការគំរាមកំហែង ឬដែលត្រូវបានគេសម្លាប់ ដោយសារការងាររបស់ពួកគេ។

ខណៈពេលដែលមានការទទួលខុសត្រូវទាំងនេះ អាចត្រូវបានគេអនុវត្តពីស្តង់ការ និងគោលការណ៍អន្តរជាតិ យន្តការនានាអំពីរបៀប និងពេលវេលាដែលគណៈមេធាវី គួរចូលរួមក្នុងបញ្ហាខាងលើ នៅតែមិនច្បាស់លាស់។ ខណៈដែលការអភិវឌ្ឍន៍ឲ្យមានការស្របមតិទូទៅលើតួនាទីរបស់គណៈមេធាវីនៅពេលមានវិវាទ នឹងអាចជួបការលំបាក ជាពិសេសសម្រាប់យុត្តាធិការដែលមានវិបត្តិ និងអំពើពុករលួយរីករាលដាល ដូចជាស្តង់ដារមានសារៈសំខាន់ទាំងអស់ក្នុងបរិបថទាំងនោះ ដើម្បីធានាភាពទទួលខុសត្រូវ និងលើកកម្ពស់យុត្តិធម៌។

## ឯកសារយោង

គណៈមេធាវីអាមេរិកាំង, 'សៀវភៅណែនាំអំពីគោលនយោបាយ និងនីតិវិធី 2014-2015' (ABA, 2014) <http://www.americanbar.org/content/dam/aba/administrative/house_of_delegates/2014-2015_policy_and_procedures_handbook_greenbook1.authcheckdam.pdf> ចូលមើលនៅថ្ងៃទី 30 តុលា 2015។

គណៈមេធាវីអាមេរិកាំង, 'ស្ត្រីក្នុងវិជ្ជាជីវៈ' (ABA, 2015) <http://www.americanbar.org/groups/women.html> ចូលមើលថ្ងៃ 30 តុលា 2015

American Bar Association Presidential Diversity Initiative, 'ភាពទីទៃពីគ្នាក្នុងវិជ្ជាជីវៈច្បាប់៖ ជំហានបន្ទាប់' (ABA, 2010)។

គណៈមេធាវីកាណាដា, 'គណៈកម្មការនីតិបញ្ញត្តិ និងកំណែទម្រង់ច្បាប់: អំពី' (CBA, 2015) http://www.cba.org/Sections/Legislation-and-Law-Reform ចូលមើលថ្ងៃ 30 តុលា 2015។

Chambliss E and Green B, 'តថភាពខ្លះអំពីគណៈមេធាវី' [2008] 57 Depaul Law Review 425.

Cheh M, 'តើគួរមេធាវីចូលរួមក្នុងប្រព័ន្ធដែលមានស្រាប់៖ ករណីស្នងការសឹក' [2005] 375 International Journal of National Security & Policy 20.

Conseil National des Barreaux de la France, 'Missions' (Conseil National des Barreaux de la France, 2012) < http://cnb.avocat.fr/Missions-du-Conseil-National-des-Barreaux_a35.html> ចូលមើលថ្ងៃ 30 តុលា 2015។

ក្រុមប្រឹក្សាឥណ្ឌា, 'វិធានរបស់ក្រុមប្រឹក្សាគណៈមេធាវីឥណ្ឌា' (ក្រុមប្រឹក្សាឥណ្ឌា, កញ្ញា 2009) <http://www.barcouncilofindia.org/wp-content/uploads/2010/05/BCIRulesPartItoIII.pdf> ចូលមើលថ្ងៃ 30 តុលា 2015)។

Cumaraswamy P, 'របាយការណ៍អំពីបេសកកម្មរបស់អ្នករាយការណ៍ពិសេសប្រចាំនៅចក្រភពអង់គ្លេស និងអៀរឡង់ខាងជើង' (UN Doc E/CN.4/1999/39/Add.4, 5 មីនា 1998)។

Despouy L, 'របាយការណ៍របស់អ្នករាយការណ៍ពិសេសអំពីឯករាជ្យភាពនៃចៅក្រម និងមេធាវី' (UN Doc A/64//181, 28 កក្កដា 2009)។

Devlin M, 'ការអភិវឌ្ឍន៍នីតិវិធីដាក់ពិន័យដល់មេធាវី នៅសហរដ្ឋអាមេរិក' [1994] Spring Georgetown Journal of Legal Ethics 385.

Dikes P, 'វិន័យ និងគណៈមេធាវីហុងកុង' (ក្រុមប្រឹក្សា IBA ពាក់កណ្តាលឆ្នាំ, Lisbon, ឧសភា 2005)។

Dugard J, 'សិទ្ធិមនុស្ស, ការរើសអើងពណ៌សម្បុរ និងមេធាវី។ តើមានមេរៀនណាមួយពីមេធាវីមកពី ប្រទេសដែលមានច្បាប់រួមឬទេ? [1991] 15 University of New South Wales Law Journal 444-445.

អគ្គគណៈមេធាវីអាហ្វ្រិកខាងត្បូង, 'អំណះអំណាងបេសកកម្ម' <http://www.sabar.co.za/about.html> ចូលមើលនៅថ្ងៃ 30 តុលា 2015។

អគ្គគណៈមេធាវីអាហ្វ្រិកខាងត្បូង, 'រដ្ឋធម្មនុញ្ញដែលមានវិសោធនកម្ម ដែលឯកភាពមកដល់ខែ កក្កដា 2012 ដូចមានក្នុងមាត្រា 2(d)' (អគ្គគណៈមេធាវីអាហ្វ្រិកខាងត្បូង 2012) <http://www.sabar.co.za/about.html> ចូលមើលថ្ងៃ 30 តុលា 2015។

អគ្គគណៈមេធាវីអាហ្វ្រិកខាងត្បូង, 'វិធានក្រមសីលធម៌រួម' (អគ្គគណៈមេធាវីអាហ្វ្រិកខាងត្បូង, 2012) <http://www.sabar.co.za/GCB-UniformRules-of-Ethics-updated-July2012.pdf> ចូលមើលថ្ងៃ 30 តុលា 2015។

គណៈមេធាវីអន្តរជាតិ, 'ស្តង់ដារ IBA សម្រាប់ឯករាជ្យភាពនៃវិជ្ជាជីវៈច្បាប់' (IBA, 1990) <http://www.ibanet.org/Document/Default.aspx?DocumentUid=f68bbba5-fd1f-426f-9aa5-48d26b5e72e7> ចូលមើលថ្ងៃ 30 តុលា 2015។

គណៈមេធាវីអន្តរជាតិ, 'IBA សំដែងការព្រួយបារម្ភចំពោះការកាត់ទោសលើមេធាវីបួនរូប, ទួគី, មករា 2004' (IBA, 20 មករា 2004) <http://www.ibanet.org/Human_Rights_Institute/About_the_HRI/HRI_Activities/HRI_Media/HRI_Interventions/archive/200104_Turkey.aspx> ចូលមើលថ្ងៃ 30 តុលា 2015.

គណៈមេធាវីអន្តរជាតិ, 'គណៈមេធាវី – វិន័យ និងច្បាប់' (សម័យប្រជុំតំណាងគណៈមេធាវី, Lisbon Portugal, 19 ឧសភា 2005) <http://www.ibanet.org/barassociations/bar_associations_disciplinary_measures.aspx> ចូលមើលថ្ងៃ 30 តុលា 2015។

គណៈមេធាវីអន្តរជាតិ, 'IBAHRI ថ្កោលទោសអំពើហិង្សា និងការគំរាមកំហែងថ្មីៗ ធ្វើឡើងប្រឆាំងនឹងមេធាវីជនជាតិហ្ស៊ីមបាវេ ដោយប៉ូលីស និងមន្ត្រីដទៃទៀត,' (IBA, 22 មីនា 2007) <http://www.ibanet.org/Article/Detail.aspx?ArticleUid=2402BBB3-3819-4511-BA6E-88FE10CAB1F1> ចូលមើលថ្ងៃ 30 តុលា 2015។

គណៈមេធាវីអន្តរជាតិ, 'សេចក្តីប្រកាសអំពីសេវាមេត្តាធម៌របស់ IBA', (IBA, 2008) <http://www.ibanet.org/Document/Default.aspx?DocumentUid=C4B06FD6-A807-44D4-A98A-C73B464589C6> ចូលមើលថ្ងៃ 30 តុលា 2015។

គណៈមេធាវីអន្តរជាតិ, 'Sri Lanka: IBAHRI ណែនាំពីការការពារសម្រាប់ប្រព័ន្ធយុត្តិធម៌ វិជ្ជាជីវៈច្បាប់ និងប្រព័ន្ធផ្សព្វផ្សាយ,' (IBA, 26 May 2009) <http://www.ibanet.org/Article/Detail.aspx?ArticleUid=7DF2962F-7769-4FAF-8E16-6371B408C174> ចូលមើលថ្ងៃ 30 តុលា 2015។

គណៈមេធាវីអន្តរជាតិ, 'គោលការណ៍នយោបាយរបស់ IBA សម្រាប់ការបណ្តុះបណ្តាល និងអប់រំនៃវិជ្ជាជីវៈច្បាប់ (Part II)' (IBA, 23 តុលា 2014)។

គណៈមេធាវីអន្តរជាតិ, 'អំពី IBA' (IBA, 2015) <http://www.ibanet.org/About_the_IBA/About_the_IBA.aspx> ចូលមើលថ្ងៃ 30 តុលា 2015។

International Commission of Jurists, 'អត្ថាធិប្បាយច្បាប់ចំពោះសេចក្តីប្រកាសនៅទីក្រុង ហ្សឺណែវ របស់ ICJ: ការលើកស្ទួយច្បាប់ និងតួនាទីរបស់ចៅក្រម និងមេធាវី ក្នុងពេលមានវិបត្តិ' (International Commission of Jurists, 31 ឧសភា 2011)។

បណ្តាញអន្តរជាតិដើម្បីលើកកម្ពស់ច្បាប់ (INPROL), 'ការបង្កើត និងកំណែទម្រង់គណៈមេធាវី ក្នុងបណ្តារដ្ឋក្រោយមានវិវាទ' (INPROL, មករា 2010)។

គណៈមេធាវីអ៊ីស្រាអែល, 'មុខងារដែលមានចែងក្នុងលក្ខន្តិកៈ' (គណៈមេធាវីអ៊ីស្រាអែល, 2015) <http://www.israelbar.org.il/english_inner.asp?pgId=103336&catId=372> ចូលមើលថ្ងៃ 30 តុលា 2015។

គណៈមេធាវីជើម៉ៃកា, 'អំពី JamBar' <http://www.jambar.org/index.php?option=com_content&view=article&id=2&Itemid=214> ចូលមើលថ្ងៃ 30 តុលា 2015។

Johnstone Q, 'គណៈមេធាវី៖ គោលនយោបាយ និងការអនុវត្តន៍' [1996] 15 Yale Law and Policy Review 195.

Judice J M, 'វិធានការវិន័យរបស់គណៈមេធាវីព័រទុយហ្កាល់' (IBA Mid-Year Council, Lisbon, ឧសភា 2005)។

គណៈមេធាវី កូសូវ៉ូ, 'ក្រមសីលធម៌វិជ្ជាជីវៈមេធាវី' (KBA, ធ្នូ 2012) <http://www.oak-ks.org/repository/docs/Code_of_Ethics_2012_(ENG)_(update_January_2014)_638576.pdf> ចូលមើលថ្ងៃ 30 តុលា 2015។

សង្គមអ្នកច្បាប់នៃសភាជាន់ខ្ពស់កាណាដា, 'ការសិក្សាអំពីសង្គមអ្នកច្បាប់ និងការស្វែងរកការអនុវត្តន៍ល្អ' (នាយកដ្ឋានផ្តួចផ្តើមដោយសមធម៌, 2014) <http://www.lsuc.on.ca/uploadedFiles/Equity_and_Diversity/Members/Challenges_for_Racialized_Licensees/law-society-studies-and-scan-of-best-practices-racialized-licensees-working-group.pdf> ចូលមើលថ្ងៃ 30 តុលា 2015។

McEvoy K, 'តើមេធាវីបានធ្វើអ្វីក្នុងពេល "សង្គ្រាម"៖ អព្យាក្រិត្យភាព វិវាទ និងវប្បធម៌នៃភាពស្ងៀមស្ងាត់' [2001] 74 The Modern Law Review 383.

McEvoy K និង Reoubche R, 'ការប្រមូលផ្តុំវិជ្ជាជីវៈ? មេធាវី នយោបាយ និងមនសិការច្បាប់រួម' ក្នុង Morrison J, McEvoy K និង Anthony G, (eds) ចៅក្រម សិទ្ធិមនុស្ស និងអន្តរកាល (Oxford, 2007)។

Mehdi R, 'ឥស្លាមតូបនីយកម្មច្បាប់ក្នុងប្រទេសប៉ាគីស្ថាន' (Curzon Press, 1994).

Mills K, 'ការការពារសិទ្ធិមនុស្សក្នុងនយោបាយសកលៈ ការទទួលខុសត្រូវនៃតួអង្គជារដ្ឋ និងមិនមែនជារដ្ឋ', (Palgrave, 2015)។

Morrison J, McEvoy K និង Anthony G, (eds) 'ចៅក្រម សិទ្ធិមនុស្ស និងអន្តរកាល' (Oxford:OUP, 2007)។

O'Flaherty M, 'ដំណើរការសន្តិភាពនៅសេរ៉ាឡេអូន,' ក្នុង Lutz E និង Babbitt E (eds) សិទ្ធិមនុស្ស និងដំណោះស្រាយវិវាទក្នុងបរិបទៈ កូឡុំបៀ សេរ៉ាឡេអូន និងអៀរឡង់ខាងជើង (Syracuse, 2009).

Rasmussen J, 'ប្រវត្តិសង្ខេបអំពីវិធីរកជំនួយបច្ចេកទេសរបស់គំនិតផ្តួចផ្តើមច្បាប់របស់គណៈមេធាវី អាមេរិកាំង' [2013] 31 Wisconsin International Law Journal 776.

Sarat A និង Scheingold S, 'អ្វីមួយត្រូវជឿៈ នយោបាយ វិជ្ជាជីវៈ និងបុព្វហេតុមេធាវី' (Stanford: OUP, 2004).

សង្គមមេធាវី ណាមីបៀ, 'កម្មវត្ថុរបស់សង្គមមេធាវីណាមីបៀ' <http://www.namibianbar.org/About.htm> ចូលមើលថ្ងៃ 30 តុលា 2015.

សង្គមអ្នកច្បាប់ខិនយ៉ា, 'កម្មវត្ថុ' (សង្គមអ្នកច្បាប់ហុងកុង, 2015) <http://www.lsk.or.ke/index.php/about-lsk> ចូលមើលថ្ងៃ 30 តុលា 2015.

សង្គមអ្នកច្បាប់ហុងកុង, 'ប្រវត្តិ' (សង្គមអ្នកច្បាប់ហុងកុង, 2015) <http://www.hklawsoc.org.hk/pub_e/about/> ចូលមើលថ្ងៃ 30 តុលា 2015។

Thompson N, 'ការស្វែងរកយុត្តិធម៌ៈ របាយការណ៍អំពីប្រព័ន្ធតុលាការនៅ សេរ៉ាឡេអូន' របាយការណ៍នៃគំនិតផ្តួចផ្តើមសិទ្ធិមនុស្ស Commonwealth និងគណៈមេធាវី សេរ៉ាឡេអូន (Commonwealth Human Rights Initiative, 2002) <http://www.humanrightsinitiative.org/publications/ffm/sierra_leone_report.pdf> ចូលមើលថ្ងៃ 30 តុលា 2015)។

Trebilock M និង Daniels R, 'កំណែទម្រង់ និងការអភិវឌ្ឍន៍ច្បាប់ៈ គំនូសមាគ៌ាប្រេះស្រាំនៃវឌ្ឍនភាព' (Edward Elgar Publishing, 2009).

គណៈកម្មការស្វែងរកការពិត និងសម្របសម្រួល, 'របាយការណ៍ចុងក្រោយ', វ៉ុលទី 4, ជំពូកទី 4, ផ្នែករង 3, 1998។

គណៈមេធាវីចក្រភពអង់គ្លេស, 'សមភាព និងភាពទីទៃពីគ្នា និងការប្រមូលផ្តុំផ្នែកសង្គម' (គណៈមេធាវីចក្រភពអង់គ្លេស, 2015) <http://barcouncil.org.uk/about-us/constitution-and-structure/committees/equality-and-diversity-committee/> ចូលមើលថ្ងៃ 30 តុលា 2015។

គណៈមេធាវីចក្រភពអង់គ្លេស, 'អំណះអំណាងបេសកកម្ម' (គណៈមេធាវីចក្រភពអង់គ្លេស, 2015) <http://www.barcouncil.org.uk/about-us/mission-statement/> ចូលមើលថ្ងៃ 30 តុលា 2015។

ការិយាល័យអង្គការសហប្រជាជាតិនៃស្នងការជាន់ខ្ពស់សម្រាប់សិទ្ធិមនុស្ស 'គោលការណ៍មូលដ្ឋានរបស់អង្គការសហប្រជាជាតិ អំពីតួនាទីនៃមេធាវី' (UNHR, កញ្ញា 1990) <http://www.ohchr.org/EN/ProfessionalInterest/Pages/RoleOfLawyers.aspx> ចូលមើលថ្ងៃ 30 តុលា 2015។

## <u>ច្បាប់យុត្តិសាស្ត្រ</u>

Keller v. រដ្ឋកាលីហ្វ័រញ៉ា [1990] (496) S.Ct. 88.